# រុក្ខជាតិចង្រៃនៃដំណាំចំការ
# ក្នុងប្រទេសកម្ពុជា

Australian Government
Australian Centre for
International Agricultural Research



មជ្ឈមណ្ឌលអូស្ត្រាលី សំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (អេសុីអាយអេអា-ACIAR) ត្រូវបានបង្កើតឡើងក្នុងខែមិថុនា ឆ្នាំ១៩៨២ ដោយច្បាប់មួយរបស់រដ្ឋសភាអូស្ត្រាលី ។ អេសុីអាយអេអា (ACIAR) ធ្វើការងារជាផ្នែកមួយនៃកម្មវិធីសហប្រតិបត្តិការណ៍អភិវឌ្ឍន៏អន្តរជាតិរបស់ប្រទេសអូស្ត្រាលី ដែលមានបេសកម្មធ្វើអោយសម្រេចនូវប្រព័ន្ធកសិកម្ម ប្រកបដោយផ្លែផ្កា និងនិរន្តរភាពសម្រាប់ជាប្រយោជន៏ដល់ប្រទេសកំពុងអភិវឌ្ឍន៏ និងប្រទេសអូស្ត្រាលី ។ អេសុីអាយអេអាផ្តល់សិទ្ធអំណាចដល់ការស្រាវជ្រាវដែលមានកិច្ចសហប្រតិបត្តិការណ៍ រវាងអ្នកស្រាវជ្រាវរបស់ប្រទេសអូស្ត្រាលី និងប្រទេសកំពុងអភិវឌ្ឍន៏នៅក្នុងតំបន់ ដែលប្រទេសអូស្ត្រាលីមានសមត្ថភាពធ្វើការស្រាវជ្រាវពិសេស ។ អេសុីអាយអេអាចាត់ចែងផងដែរនូវជំនួយពីរដ្ឋាភិបាលអូស្ត្រាលី សំរាប់មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិ ។

ការប្រើប្រាស់ឯកសារ (ឈ្មោះពាណិជ្ជកម្មនៃសៀវភៅ) នេះ គឺមិនត្រូវបានចាត់ទុកថាជាការគាំទ្រ ឬក៏ជាការរើសអើងដល់ស្នាដៃរបស់មជ្ឈមណ្ឌលឡើយ ។

## ស៊េរីសៀវភៅឯកលេខរបស់ អេសុីអាយអេអា (ACIAR)

ស៊េរីសៀវភៅនេះមានផ្ទុកនូវលទ្ធផលនៃការស្រាវជ្រាវដំបូង ដែលផ្តល់ដោយ អេសុីអាយអេអា ឬពត៌មានដែលចាត់ទុកថាមានភាពសមស្របទៅនឹងគោលបំណងនៃការស្រាវជ្រាវ និងការអភិវឌ្ឍន៏របស់ អេសុីអាយអេអា (ACIAR) ។ ស៊េរីសៀវភៅនេះត្រូវបានចែកចាយជាអន្តរជាតិ ដោយផ្តោតជាសំខាន់លើប្រទេសដែលកំពុងអភិវឌ្ឍន៏ ។

© រដ្ឋាភិបាលអូស្ត្រាលី ២០០៩

សៀវភៅនេះ គឺជាការរក្សាសិទ្ធិ ។ លើកលែងតែការប្រើប្រាស់ណាមួយ ដែលត្រូវបានអនុញ្ញាតិដោយច្បាប់រក្សាសិទ្ធិ ឆ្នាំ១៩៦៨ ។ គ្មានផ្នែកណាមួយនៃសៀវភៅនេះអាចនឹងត្រូវបានផលិតឡើងវិញ ដោយគ្មានការសរសេរសុំការអនុញ្ញាតិពីរដ្ឋឡើយ ។ ការស្នើរសុំ និងការសួរនាំផ្សេង១ដែលទាក់ទងនឹងការផលិតឡើងវិញ និងសិទ្ធិទាំងឡាយ គួរតែទាក់ទងស្នើរសុំការអនុញ្ញាតិពីផ្នែករដ្ឋបាលដែលទទួលបន្ទុកការងាររក្សាសិទ្ធិរបស់រដ្ឋនៃនាយកដ្ឋានអគ្គមេធាវី ការិយាល័យ Robert Garran Offices, National Circuit, Barton ACT 2600 ឬដាក់ផ្ញើតាម <http://www.ag.gov.au/cca> ។

**បោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវ កសិកម្មអន្តរជាតិ (អេសុីអាយអេអា – ACIAR)**

ប្រអប់សំបុត្រ: 1571, Canberra ACT 2601, Australia

ទូរស័ព្ទលេខ: 61 2 6217 0500

អុីម៉ែល: aciar@aciar.gov.au

បោះពុម្ពផ្សាយលើកដំបូង ជាភាសាអង់គ្លេស ក្នុងឆ្នាំ២០០៧ ដោយនាយកដ្ឋានឧស្សាហ៏កម្មបឋមញូសាវេល (New South Wales Department of Primary Industries) ដែលឥឡូវត្រូវបានស្គាល់ថាជានាយកដ្ឋានឧស្សាហ៏កម្ម និងវិនិយោគ នៃរដ្ឋញូសាវេល (Industry & Investment NSW) ។

ម៉ាទីន អា (Martin R.) និង ប៉ុល ស៊ី (Pol C.) ២០០៩ ។ រុក្ខជាតិចង្រៃនៃដំណាំចំការ ក្នុងប្រទេសកម្ពុជា ។ ស៊េរីសៀវភៅឯកលេខរបស់ អេសុីអាយអេអា (ACIAR) លេខ១៤១ ទំព័រ៨១ (No. 141, 81 pp) ។

បកប្រែដោយ កែវ គីណាល់

ការបកប្រែពិនិត្យមើលឡើងវិញដោយ មាឌ ផល្លា និង វ៉ាន់ ទូច

ការបកប្រែមើលកែដោយ សុខ មុន្នីរ័ត្ន

ISBN 978 1 921531 66 8 (បោះពុម្ព)

ISBN 978 1 921531 67 5 (អុីនធើណិត)

# រុក្ខជាតិចង្រៃនៃដំណាំចំការ ក្នុងប្រទេសកម្ពុជា

ការណែនាំ (មគ្គុទ្ទេសក៍)ពីការកំណត់អត្តសញ្ញាណរុក្ខជាតិចង្រៃ សម្រាប់កសិករ និងអ្នកផ្សព្វផ្សាយក្នុងប្រព័ន្ធដាំដុះដំណាំចំការ នៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា។ ឧបត្ថម្ភដោយ មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ នាយកដ្ឋានឧស្សាហ៍កម្មបឋមញូសាវេល (NSW) និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។

NSW DEPARTMENT OF
**PRIMARY INDUSTRIES**

**ACIAR**
www.aciar.gov.au

លោកសាស្ត្រាចារ្យ រ៉ូប៊ឺត ម៉ាទីន (ROBERT MARTIN) និងលោកប៉ុល ចាន់ធី (POL CHANTHY)

# អារម្ភកថា

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ (២០០៣-២០០៥) របស់រាជរដ្ឋាភិបាលកម្ពុជា បានជម្រុញលើកទឹកចិត្តមជ្ឈមណ្ឌលស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយឱ្យផ្តោតលើកសិករខ្នាតតូច ការប្រើប្រាស់ឧបករណ៍ និងការអនុវត្តន៍ការគ្រប់គ្រងដែលសមស្របសម្រាប់ប្រព័ន្ធដាំដុះ។ ជាអាទិភាព គឺផ្តល់នូវភាពចម្រុះ និងប្រពលវប្បកម្មនៃផលិតកម្មកសិកម្ម ដែលមាននិរន្តរភាព ដោយប្រើប្រាស់ធនធានពីខាងក្រៅតិចតួច ព្រមទាំងការអនុវត្តន៍ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពក្នុងការចំណាយ។

មជ្ឈមណ្ឌលអូស្ត្រាលី សំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (អេស៊ីអាយអេអា- ACIAR) បានទទួលការប្រឈមទាំងនេះនៅក្នុងឆ្នាំ២០០៣ ដោយការចាប់ផ្តើមនូវគំរោងមួយដើម្បីអភិវឌ្ឍន៍ប្រព័ន្ធកសិកម្មដែលមាននិរន្តរភាពសំរាប់ដំណាំចម្រុះ (ASEM/2000/109)។ គំរោងផ្តោតទៅលើដំណាំពោត សណ្តែកសៀង ល្ង សណ្តែកបាយ សណ្តែកដី និងសណ្តែកអង្គុយនៅតំបន់ខ្ពង់រាបនៃខេត្តកំពង់ចាម និងបាត់ដំបង។ គោលបំណងនៃគម្រោងគឺជួយកាត់បន្ថយភាពក្រីក្រ និងចូលរួមចំណែកធ្វើឱ្យមានសន្តិសុខស្បៀងតាមគ្រួសារ និងថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជាតាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យា និងឱកាសសម្រាប់ផលិតកម្មដំណាំចំការ នៅតំបន់ខ្ពង់រាបដែលមិនមែនជាស្រូវ។ ដំណើរការស្រាវជ្រាវរួមមានការពិភាក្សាជាមួយកសិករ ការស្វែងយល់ពីចំណេះដឹងជាប្រពៃណីរបស់កសិករ ការចងក្រងឯកសារនៃការសិក្សាស្វែងយល់តាមករណី និងអាទិភាពក្នុងការកំណត់អត្តសញ្ញាណសម្រាប់ការធ្វើពិសោធន៍តាមចំការ។

ក្រុមគម្រោងបានធ្វើពិសោធន៍ស្រាវជ្រាវ និងធ្វើបង្ហាញតាមចំការសរុបចំនួន១៥៣ ក្នុងចន្លោះឆ្នាំ២០០៤-២០០៦។ ការស្រាវជ្រាវនេះផ្តល់ជាមូលដ្ឋាន សំរាប់ការធ្វើពិសោធន៍បង្ហាញនូវបទដ្ឋានអនុវត្តបច្ចេកវិទ្យាថ្មីៗ លើផលិតកម្មដំណាំចំការ។ បទដ្ឋានអនុវត្តបច្ចេកវិទ្យារួមមានពូជរំដោះចេញ ការផ្តល់អនុសាសន៍លើការប្រើប្រាស់ជី ការប្រើរ៉ៃហ្សូប៊ីយ៉ូម *(Rhizobium)* ការកាត់បន្ថយការភ្ជួររាស់ដី និងការរក្សាកាកសំណល់ដំណាំក្នុងចំការ។ បុគ្គលិកមន្ទីរកសិកម្មខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនៅខេត្តបាត់ដំបង និងកំពង់ចាមត្រូវបានបណ្តុះបណ្តាលពីការអនុវត្តន៍ការធ្វើបង្ហាញតាមចំការនៃបទដ្ឋានអនុវត្តបច្ចេកវិទ្យាថ្មីៗនៅក្នុងឆ្នាំ២០០៧។

គម្រោងអេស៊ីអាយអេអា (ACIAR) ថ្មីមួយបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៨ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវផលិតកម្ម និងទីផ្សារ សណ្តែកសៀង និងពោតនៅភាគពាយព្យនៃប្រទេសកម្ពុជា (ASEM/2006/130)។ គម្រោងថ្មីនេះផ្តោតទៅលើការធ្វើពិសោធន៍បង្ហាញតាមចំការ ដែលអាចធ្វើឱ្យមានការផ្លាស់ប្តូរដើម្បីវាយតម្លៃ និងកែរលំអរនូវបទដ្ឋានអនុវត្តបច្ចេកវិទ្យាដែលបានពិសោធន៍សាកល្បងជាលើកដំបូងនៅក្នុងឆ្នាំ២០០៧។ គម្រោងថ្មីនេះត្រូវបានពង្រីកផងដែរ ដើម្បីដាក់បញ្ចូលផ្នែកផលិតកម្ម និងទីផ្សាររួមគ្នានៃប្រព័ន្ធផលិតកម្មកសិកម្ម។

សៀវភៅនេះគឺជាផ្នែកមួយនៃស៊េរីសៀវភៅ ដែលបានបោះពុម្ពផ្សាយ ផលិតដោយអេស៊ីអាយអេអា (ACIAR) ក្នុងការគាំទ្រនៃការធ្វើបង្ហាញតាមចំការ ដែលកំពុងបន្តអនុវត្តសម្រាប់ដំណាំចំការនៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា



និក អូស្ទីន (Nick Austin)
អគ្គនាយក
អេស៊ីអាយអេអា (ACIAR)

# មាតិកា


កថាមុខ i
មាតិកាឈ្មោះជាភាសាខ្មែរ iv
អារម្ភកថា vi
សេចក្ដីថ្លែងអំណរគុណ vi
ការគ្រប់គ្រងរុក្ខជាតិចង្រៃ ១
ការអនុវត្តន៍តាមប្រពៃណី ១
វិធានការគ្រប់គ្រងចំរុះ ១
ការផ្ដល់ជាចំណីសត្វ ២
ការអនុវត្តន៍បានល្អតាម
បែបក្សេត្រសាស្ត្រ ២
ការគ្រប់គ្រងរុក្ខជាតិចង្រៃទាន់ពេលវេលា ៣
ការអោយសត្វស៊ី
វិការដុតចោល ៣
រុក្ខជាតិចង្រៃសំខាន់ៗ ៤
ការពិពណ៌នាអំពីរុក្ខជាតិចង្រៃ ៥
អត្តសញ្ញាណរុក្ខជាតិចង្រៃ ៥
សេចក្ដីណែនាំអំពីការប្រើប្រាស់សៀវភៅ ៥
គ្រួសារ Acanthaceae
ស្មៅគ្រាប់បែក (Ruellia tuberosa) ៦
គ្រួសារ Aizoaceae
ផ្ទីថ្ម (Trianthema portulacastrum) ៧
គ្រួសារ Amaranthaceae
ស្មៅអណ្ដាតគោ (Achryanthes aspera) ៨
ស្មៅជើងបង្កង(Alternanthera sessilis) ៩
ផ្ទីបន្លា (Amaranthus spinosus) ១០
ផ្ទីដូង (Amaranthus viridus) ១១
ស្មៅសិរមាន់ព្រៃ/ផ្ទីព្រះ
(Celosia argentea) ១២
គ្រួសារ Apiaceae
វល្លិត្រចៀកក្រាញ់ (Centella asiatica) ១៣
គ្រួសារ Asteraceae
ទន្ទ្រានខេត្តស្វាយ (Ageratum conzoides) ១៤
ទន្ទ្រានខេត្តស (Chromolaena odorata) ១៥
មុខឈ្លាង (Eclipta alba) ១៦
ដើមចំអេះ (Spilanthes paniculata) ១៧
ស្លែគោក (Synedrella nodiflora) ១៨
ស្មៅស៊ីករណា (Tridax procumbens) ១៩
ឥសីផ្សំស្រេច (Vernonia cinerea) ២០
គ្រួសារ Boraginaceae
ស្មៅប្រម៉ោយដំរី
(Heliotropium indicum) ២១
គ្រួសារ Capparidaceae
មមាញស្រុក (Cleome gynandra) ២២
មមាញខ្មោចក្រហម
(Cleome rutidosperma) ២៣
មមាញខ្មោចលឿង (Cleome viscosa) ២៤
គ្រួសារ Commelinaceae
ស្មៅចំពុះទា (Cyanotis axillaris) ២៥
ស្មៅស្លាបទា (Commelina benghalensis) ២៦
គ្រួសារ Convolvulaceae
ដើមផ្កាកណ្ដឹងគោ (Ipomoea cairica) ២៧
វល្លិមួយលិប (Ipomoea obscura) ២៨
ដើមសណ្ដាដូ (Ipomoea triloba) ២៩
គ្រួសារ Cucurbitaceae
ស្ពឹកចាស (Trichosanthes cucumerina) ៣០
គ្រួសារ Cyperaceae
ស្មៅក្រវាញជ្រូក (Cyperus rotundus) ៣១
គ្រួសារ Euphorbiaceae
ស្មៅពុកមាត់ឆ្មា (Acalypha indica) ៣២
ទឹកដោះខ្លាតូច (Chamaesyce hirta) ៣៣
ទឹកដោះខ្លាធំ (Euphorbia heterophylla) ៣៤

ទឹកដោះខ្លាក្រហម
(Euphorbia thymifolia) ៣៥
ល្ហុងខ្វង (Jatropha curcas) ៣៦
ល្ហុងខ្វងក្រហម (Jatropha gossypiifolia) ៣៧
ស្មៅប្រក់ផ្លែ (Phyllanthus niruri) ៣៨

**គ្រួសារ Fabaceae**
ស្មៅអំពោះ (Aeschynomene americana) ៣៩
ដើមសន្ទះឌីម៉ាល់ (Alysicarpus monilifer) ៤០
សណ្តែកខ្មោច (Cassia occidentalis) ៤១
ដង្ហិតឈ្មោល ឬដង្ហិតខ្មោច (Cassia tora) ៤២
វល្លិ៍កន្ទុយ (Centrosema pubescens) ៤៣
ស្មៅអញ្ចាន់ (Clitoria ternatea) ៤៤
ស្មៅចង្រង់ស្វា (Crotalaria striata) ៤៥
បន្លាស្អិត (Mimosa invisa) ៤៦
ព្រះខ្លបយក្ស (Mimosa pigra) ៤៧
ព្រះខ្លប (Mimosa pudica) ៤៨
វល្លិ៍កន្ទុយកណ្តុរ
(Macroptilium atropurpureus) ៤៩

**គ្រួសារ Lamiaceae**
ដើមម្រេចទន្សាយ (Hyptis suaviolens) ៥០

**គ្រួសារ Malvaceae**
ម្ជូរព្រឹកព្រៃ (Abelmoschus moschatus) ៥១
ត្បាល់កិន (Abutilon indicum) ៥២
ក្រជិប (Pentapetes phoenicea) ៥៣
កន្ទ្រាំងបាយស (Sida acuta) ៥៤
កន្ទ្រាំងបាយសញ្ញី (Sida rhombifolia) ៥៥
ស្មៅអាចម៍ជ្រូក (Urena lobata) ៥៦

**គ្រួសារ Nyctaginaceae**
ផ្ទីថ្មឈ្មោល (Boerhavia diffusa) ៥៧

**គ្រួសារ Passifloraceae**
សាវម៉ាវព្រៃ (Passiflora foetida) ៥៨

**គ្រួសារ Poaceae**
ស្មៅចារាំង (Brachiaria mutica) ៥៩
ស្មៅគោ (Brachiaria reptans) ៦០
ស្មៅចិញ្ចៀន (Cynodon dactylon) ៦១
ស្មៅជើងក្រាស់
(Dactyloctenium aegyptium) ៦២
ស្មៅសំបុកមាន់ (Digitaria adscendens) ៦៣
ស្មៅបែកក្បាលគ្មានកន្ទុយ
(Echinochloa colona) ៦៤
ស្មៅទន្សោង (Eleusine indica) ៦៥
ស្បូវ (Imperata cylindrica) ៦៦
ព្រែង (Sorghum halepense) ៦៧

**គ្រួសារ Portulacaceae**
ក្បិតជូន (Portulaca oleracea) ៦៨

**គ្រួសារ Rubiaceae**
ម្អមភ្នំញី (Borreria alata) ៦៩
កំពោយចិន (Hedyotis diffusa) ៧០
ម្អមភ្នំឈ្មោល (Richardia brasiliensis) ៧១

**គ្រួសារ Sapindaceae**
អំបែងបែក (Cardiospermum halicacabum) ៧២

**គ្រួសារ Solanaceae**
ប៉េងប៉ោះស្រោម (Physalis angulata) ៧៣

**គ្រួសារ Tiliaceae**
ក្រចៅព្រៃ (Corchorus olitorius) ៧៤

**គ្រួសារ Verbenaceae**
ស្មៅគ្រាប់ស្អិត (Stachytarpheta indica) ៧៥

**គ្រួសារ Vitaceae**
វល្លិ៍ត្រដិត (Cayratia trifolia) ៧៦

**សន្ទានុក្រម** ៧៧

**ឯកសារយោង** ៨១

# មាតិការឈ្មោះជាភាសាខ្មែរ


ស្មៅអាចម៍ជ្រូក
*Urena lobata* ៥៦

ស្មៅអំបែងបែក
*Cardiospermum halicababum* ៧២

ស្មៅអណ្ដាតគោ
*Achryanthes aspera* ៨

ស្មៅអញ្ជ៊ន
*Clitoria ternatea* ៤៤

ស្មៅប្រក់ផ្លែ
*Phyllanthus niruri* ៣៨

កន្ទ្រាំងបាយស
*Sida acuta* ៥៤

កន្ទ្រាំងបាយសញ្ញី
*Sida rhombifolia* ៥៥

កំប៉ោយចិន
*Hedyotis diffusa* ៧០

ក្បិតជូន
*Portulaca oleracea* ៦៨

ក្រចៅព្រៃ
*Corchorus olitorius* ៧៤

ក្រជិប
*Pentapetes phoenicia* ៥៣

ដង្កិតខ្មោច
*Cassia tora* ៤២

ដើមផ្កាកណ្ដឹងគោ
*Ipomoea cairica* ២៧

ដើមចំអេះ
*Spilanthes paniculata* ១៧

ដើមម្រេចទន្សាយ
*Hyptis suaviolens* ៥០

ដើមសណ្ដាជូ
*Ipomoea triloba* ២៩

ដើមសន្ទះឪម៉ាល់
*Alysicarpus monilifer* ៤០

ត្បាល់កិន
*Abutilon indicum* ៥២

ព្រ៉ែង
*Sorghum halepense* ៦៧

ទន្ទ្រានខេត្តស
*Chromolaena odorata* ១៥

ទន្ទ្រានខេត្តស្វាយ
*Ageratum conzoides* ១៤

ទឹកដោះខ្លាតូច
*Chamaesyce hirta* ៣៣

ទឹកដោះខ្លាធំ
*Euphorbia heterophylla* ៣៤

ប៉េងប៉ោះស្រោម
*Physalis angulata* ៧៣

ផ្ទីដូង
*Amaranthus viridus* ១១

ផ្ទីថ្មឈ្មោល
*Boerhavia diffusa* ៥៧

ផ្ទីថ្មញី
*Trianthema portulacastrum* ៧

ផ្ទីបន្លា
*Amaranthus spinosus* ១០

ព្រះខ្លប
*Mimosa pudica* ៤៨

ព្រះខ្លបដំរី
*Mimosa invisa* ៤៦

ព្រះខ្លបយក្ស
*Mimosa pigra* ៤៧

មមាញខ្មោចក្រហម
*Cleome rutidosperma* ២៣

មមាញខ្មោចលឿង
*Cleome viscosa* ២៤

មមាញស្រុក
*Cleome gynandra* ២២

មុខឈ្មាង
*Eclipta alba* ១៦

ម្ទូរព្រឹកព្រៃ
*Abelmoschus moschatus* ៥១

ម្អមភ្នំញី
*Borreria alata* ៦៩

ល្ហុងខ្វង
*Jatropha curcas* ៣៦

ល្ហុងខ្វងក្រហម
*Jatropha gossypiifolia* ៣៧

វល្លិ៍កន្ទុយ
*Centrosema pubescens* ៤៣

វល្លិ៍កន្ទុយកណ្ដុរ
*Macroptilium atropurpureum* ៤៩

វល្លិ៍ត្រចៀកក្រាញ់
*Centella asiatica* ១៣

វល្លិ៍ត្រដិត
*Cayratia trifolia* ៧៦

វល្លិ៍មួយលិប
*Ipomoea obscura* ២៨

សណ្ដែកខ្មោច
*Cassia occidentalis* ៤១

សាវម៉ាវព្រៃ
*Passiflora foetida* ៥៨

ស្បូវ
*Imperata cylindrica* ៦៦

ស្ពៃគោក
*Syndrella nodiflora* ១៨

ស្ងឹកបាស
*Trichosanthes cucumerina* ៣០

ស្លាបទា
*Commelina benghalensis* ២៦

ស្មៅក្រវាញជ្រូក
*Cyperus rotundus* ៣១

ស្មៅគោ
*Brachiaria reptans* ៦០

ស្មៅគ្រាប់បែក
*Ruellia tuberosa* ៦

ស្មៅគ្រាប់ស្អិត
*Stachytarpheta indica* ៧៥

ស្មៅចង្រ្កង់ស្វា
*Crotalaria striata* ៤៥

ស្មៅចិញ្ចៀន
*Cynodon dactylon* ៦១

ស្មៅចំពុះទា
*Cyanotis axillaris* ២៥

ស្មៅជើងក្រាស់
*Dactyloctenium aegyptium* ៦២

ស្មៅជើងបង្កង
*Alternanthera sessilis* ៩

ស្មៅប្រម៉ោយដំរី
*Heliotropium indicum* ២១

ស្មៅបែកក្បាលគ្មានកន្ទុយ
*Echinochloa colona* ៦៤

ស្មៅបារាំង
*Brachiaria mutica* ៥៩

ស្មៅពុកមាត់ឆ្មា
*Acalypha indica* ៣២

ស្មៅសិរមាន់ព្រៃ
*Celosia argentea* ១២

ស្មៅសំបុកមាន់
*Digitaria adscendens* ៦៣

ស្មៅសំរោង
*Eleusine indica* ៦៥

ស្មៅអំបោះ
*Aeschynomone americana* ៣៩

អំបែងបែក
*Cardiospermum halicacabum* ៧២

តសីផ្សំស្រេច
*Vernonia cinerea* ២០

# អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

## អារម្ភកថា

គោលបំណងនៃសៀវភៅនេះ គឺជួយអ្នកផ្សព្វផ្សាយ និងកសិករដើម្បីកំណត់អត្តសញ្ញាណរុក្ខជាតិ ដែលជារុក្ខជាតិចង្រៃ ឬត្រូវបានគិតថាមានសក្តានុពលក្លាយជារុក្ខជាតិចង្រៃ នៅក្នុងប្រព័ន្ធដាំដុះដំណាំចំការក្នុងប្រទេសកម្ពុជា។ គ្រប់រុក្ខជាតិដែលមានរាយឈ្មោះក្នុងសៀវភៅនេះ មិនត្រូវបានគិតថាជារុក្ខជាតិចង្រៃទាំងអស់នោះទេ ផ្ទុយទៅវិញ ក្នុងចំណោមរុក្ខជាតិទាំងនេះជាច្រើនត្រូវបានចាត់ទុកថាមានប្រយោជន៍។ តែដោយមានការផ្លាស់ប្តូរការអនុវត្តន៍ក្នុងការដាំដុះ ដូចជាការកាត់បន្ថយ ឬការមិនភ្ជួររាស់ ប្រភេទរុក្ខជាតិមួយចំនួនដែលថ្មីៗនេះបានធ្វើការគ្រប់គ្រងដោយការភ្ជួររាស់ អាចនឹងក្លាយជារុក្ខជាតិចង្រៃ។ រុក្ខជាតិទាំងនេះរួមមានប្រភេទរុក្ខជាតិពហុវស្ស និងរុក្ខជាតិដែលមានដើមនៅក្រោមដី និងមើម។ ប្រភេទសំខាន់ៗមួយចំនួនទៀតដែលត្រូវបានស្គាល់ថាជា រុក្ខជាតិចង្រៃក្នុងដំណាំចំការមិនត្រូវបានរួមបញ្ចូលនៅក្នុងសៀវភៅនេះទេ ដោយសារពុំមានសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ ឬពុំមានរូបភាពសមរម្យអំពីរុក្ខជាតិទាំងនេះ។


## សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះត្រូវបានបង្កើតឡើងជាផ្នែកមួយ នៃគម្រោងរបស់មជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ អេស៊ីអាយអេអា (ACIAR) គឺគំរោង ASEM/២០០០/១០៩ "ប្រព័ន្ធដាំដុះសម្រាប់ពិពិធកម្ម (ចម្រុះភាព ឬផ្សេងៗគ្នា) ដំណាំនៅប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលី"។ គម្រោងនេះបានទទួលមូលនិធិ និងឧបត្ថម្ភគាំទ្រដោយអេស៊ីអាយអេអា (ACIAR) នាយកដ្ឋានឧស្សាហ៍កម្មបឋម ញូសាវេល (NSW Department of Primary Industries) និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។ សូមថ្លែងអំណរគុណផងដែរនូវការជួយជ្រោមជ្រែង និងឧបត្ថម្ភគាំទ្រពីសមាជិកដទៃទៀតនៃក្រុមរបស់គំរោងដូចជាលោក Jeff Esdaile កញ្ញាចាន់ផលលឿន លោកអ៊ុង សុភាព និងលោកពិន តារា។ ក្នុងឆ្នាំ២០០៥ មានអ្នកស្ម័គ្រចិត្តអូស្ត្រាលី២នាក់ គឺ Wes Leedham និង Kelly Baker ដែលបានជួយក្នុងការថតរូបភាព និងធ្វើការកំណត់អត្តសញ្ញាណរុក្ខជាតិចង្រៃជាច្រើនប្រភេទ នៅក្នុងខេត្តកំពង់ចាម។ បុគ្គលិកផ្សព្វផ្សាយនៃមន្ទីរកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម និងបាត់ដំបង បានជួយជ្រោមជ្រែងផងដែរក្នុងការរៀបចំសិក្ខាសាលាជាមួយកសិករ ដើម្បីកំណត់បញ្ហារុក្ខជាតិចង្រៃឈ្មោះដែលធ្លាប់ប្រើ ដោយកសិករវិធីសាស្ត្រគ្រប់គ្រង និងផលប្រយោជន៍រុក្ខជាតិទាំងនោះ។

# ការគ្រប់គ្រងរុក្ខជាតិចង្រៃ

រុក្ខជាតិចង្រៃអាចជាបញ្ហាដល់ផលិតកម្មដំណាំចម្ការ ព្រោះវាធ្វើឱ្យទិន្នផលដំណាំថយចុះ ដោយការប្រជែងស្រូបយកធាតុសំខាន់ៗសម្រាប់ការលូតលាស់ ដូចជាទឹក អាហារូបត្ថម្ភ និងពន្លឺ។ រុក្ខជាតិចង្រៃអាចធ្វើឱ្យមានការពិបាកផងដែរ ក្នុងការប្រមូលផលដំណាំ ដោយគ្រាប់នៃប្រភេទរុក្ខជាតិចង្រៃមួយចំនួនអាចលាយឡំជាមួយគ្រាប់ដំណាំ ដែលអាចធ្វើឱ្យគុណភាព និងតម្លៃនៃគ្រាប់ដំណាំថយចុះ។

## ការអនុវត្តន៍តាមប្រពៃណី

រុក្ខជាតិចង្រៃបានចោទជាបញ្ហា តាំងពីការចាប់ផ្តើមកសិកម្មដំបូងរហូតដល់មានការផ្សាយអោយប្រើថ្នាំសំលាប់ស្មៅ កំឡុងទសវត្សឆ្នាំ១៩៤០។ ការអនុវត្តន៍តាមប្រពៃណី គឺការកំចាត់រុក្ខជាតិចង្រៃដោយដៃ ការរៀបចំដី និងការទទួលយកដោយទុករុក្ខជាតិចង្រៃក្នុងចំការ (Holm et al. ១៩៧៧)។ នៅក្នុងប្រទេសកម្ពុជារុក្ខជាតិចង្រៃនៅតែត្រូវបានគ្រប់គ្រងភាគច្រើន តាមប្រពៃណីនៅឡើយ (រូបភាព១)។

ទោះជាយ៉ាងណាក៏ដោយ កំណើនតម្លៃកម្លាំងពលកម្ម គ្រឿងយន្ត និងប្រេងឥន្ធនៈអាចនឹងមានការផ្លាស់ប្តូរច្រើនជាងមុន ទៅប្រើថ្នាំសំលាប់ស្មៅ និងបន្ថយការភ្ជួររាស់ដីនៅថ្ងៃអនាគត។

## វិធានការគ្រប់គ្រងចំរុះ

នៅតំបន់ខ្ពង់រាបក្នុងប្រទេសកម្ពុជា ទឹកជាកត្តាសំខាន់បំផុតដែលធ្វើឱ្យសក្តានុពលទិន្នផលដំណាំធ្លាក់ចុះ។ ដំណាំអាចមិនបានផលដោយសារភាពរាំងស្ងួត ជាពិសេសនៅដើមរដូវវស្សាពេលដែលទឹកភ្លៀងប្រែប្រួល និងមិនអាចទុកចិត្តបាន។ ការគ្រប់គ្រងរុក្ខជាតិចង្រៃបានល្អ គឺសំខាន់ក្នុងលក្ខខណ្ឌបែបនេះ ជាពិសេសមុនពេលដាំ ដើម្បីជៀសវាងការស្រូបយកសំណើមក្នុងដីដោយរុក្ខជាតិចង្រៃ។

កសិករត្រូវបានលើកទឹកចិត្ត ឱ្យប្រើវិធានការគ្រប់គ្រងចម្រុះរុក្ខជាតិចង្រៃ ដែលរួមបញ្ចូលគ្រប់ជម្រើសទាំងអស់ដែលអាចធ្វើបាន។ គោលបំណងនៃវិធានការនេះ គឺដើម្បីរក្សាទុករុក្ខជាតិចង្រៃឱ្យមានចំនួនតិចតួច និងការពារកុំឱ្យដាក់គ្រាប់ពេញមួយវដ្តជីវិតនៃដំណាំ។ ទោះជាយ៉ាងណាក៏ដោយ រុក្ខជាតិចង្រៃច្រើនប្រភេទនៅតំបន់ខ្ពង់រាបមានប្រយោជន៍ សម្រាប់ធ្វើជាចំណីសត្វ ឬប្រើប្រាស់ធ្វើជាបន្លែ។ ដូច្នេះតុល្យភាពក្នុងការគ្រប់គ្រងរុក្ខជាតិចង្រៃអាចជាតំរូវការចាំបាច់ ដើម្បីផ្តល់ដល់ការប្រើប្រាស់ទាំងនេះ ដោយមិនកាត់បន្ថយផលចំណេញច្រើនពីដំណាំចម្ការ។



*រូបភាពទី១: ការភ្ជួររាស់ដីតាមប្រពៃណី*

កសិករគួរគិតអំពីរបៀបគ្រប់គ្រងរុក្ខជាតិចង្រៃឱ្យបានល្អ មុននឹងដាំដំណាំ។ មធ្យោបាយនេះការពាររុក្ខជាតិចង្រៃក្នុងដំណាំមិនឱ្យដាក់គ្រាប់បាន និងគ្រប់គ្រងរុក្ខជាតិចង្រៃជុំវិញតាមព្រំចម្ការ បណ្តោយចង្អូរទឹក និងទីទំនេរជិតចំការដំណាំ។ ការយកចិត្តទុកដាក់ពិសេស ជាការចាំបាច់ទៅលើរុក្ខជាតិចង្រៃ ដូចជាប្រភេទស្មៅដែលមានមើម ស្មៅក្រវាញជ្រូក (Cyperus rotundus) ដែលដុះលូតលាស់ ពីឫស ឬមើមក្រោមដី។ រុក្ខជាតិចង្រៃប្រភេទនេះ គឺពិបាកក្នុងការគ្រប់គ្រងដោយការភ្ជួររាស់ ព្រោះរុក្ខជាតិនឹងដុះចេញពីផ្នែកដែលនៅក្រោមដី បន្ទាប់ពីដំណាំត្រូវបានដាំរួច។ ការអនុវត្តន៍មួយចំនួនដែលត្រូវបានប្រើនៅក្នុងកម្មវិធីចម្រុះគ្រប់គ្រងរុក្ខជាតិចង្រៃ ត្រូវបានរៀបរាប់ដូចខាងក្រោម។

## ការធ្វើជាចំណីសត្វ

រុក្ខជាតិចង្រៃ ជាពិសេសគឺស្មៅឯកវត្ស អាចអោយសត្វស៊ីដោយផ្ទាល់ ឬច្រូតកាត់ដោយដៃយកធ្វើជាចំណីសត្វ (រូបភាព២)។

ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ដែលរុក្ខជាតិចង្រៃត្រូវបានការពារពីការដាក់គ្រាប់។ គួរកត់សំគាល់ថាមានការផ្លាស់ប្តូរមួយគួរពិចារណា រវាងបរិមាណទឹកក្នុងដីដែលប្រើដោយរុក្ខជាតិចង្រៃ និងបរិមាណទឹកក្នុងដីដែលត្រូវការដោយដំណាំ។ ទឹកក្រោមដីមានសារៈសំខាន់ នៅដើមរដូវវស្សានៅពេលដែលមានវត្តមានទឹកក្រោមដី មុនពេលដាំដំណាំអាចជួយការពារដំណាំមិនអោយខូចដោយភាពរាំងស្ងួត។

## ការអនុវត្តន៍បានល្អតាមបែបក្សេត្រសាស្ត្រ

ការអនុវត្តន៍បានល្អតាមបែបក្សេត្រសាស្ត្រ រួមមានធ្វើអោយប្រាកដថាគ្រាប់ពូជដំណាំសំរាប់ដាំដុះគឺស្អាតល្អ គ្មានលាយគ្រាប់រុក្ខជាតិដទៃ មានភាគរយដំណុះខ្ពស់ និងកូនដំណាំថ្លោសមានកំលាំង ដែលអាចដុះលូតលាស់លឿន និងប្រកួតប្រជែងបានល្អជាមួយរុក្ខជាតិចង្រៃ។ ចំនួនដើមដំណាំត្រូវតែសមស្របទៅនឹងល័ក្ខខ័ណ្ឌនេះ។ ជាអនុសាសន៍ អត្រាគ្រាប់ពូជដែលដាំដោយពឹងផ្អែកលើរបបទឹកភ្លៀង ជាទូទៅទាបជាងការប្រើប្រព័ន្ធស្រោចស្រព។ នេះគឺជាការសំខាន់ ជាពិសេសសម្រាប់ប្រភេទដំណាំដែលដើមមិនអាចដុះលូតលាស់បន្តទៀតបាន បន្ទាប់ពីប្រមូលផលរួចដូចជាដំណាំពោត ជាដើម។



*រូបភាពទី២: ស្មៅចង្រៃដែលបានមកពីការច្រូតកាត់ក្នុងដំណាំសណ្តែកសៀង សំរាប់ធ្វើជាចំណីសត្វ។ ការសំអាតស្មៅចង្រៃក្នុងចំការឃើតយ៉ាវ អាចកាត់បន្ថយសក្តានុពលទិន្នផលដំណាំ។*

## ការគ្រប់គ្រងរុក្ខជាតិចង្រៃទាន់ពេលវេលា

### ជាទំលាប់ ការភ្ជួររាស់ដី មានគោលបំណងពីរ គឺ ...

ការសម្លាប់ស្មៅ និងការរៀបចំថ្នាលដំណាំ។ តែការភ្ជួររាស់ដីក៏អាចកាត់បន្ថយបរិមាណទឹកក្នុងដី ដែលចាំបាច់សម្រាប់ដំណាំផងដែរ។ ប្រភេទដីតំបន់ខ្ពង់រាបខ្លះ ដូចជា ប្រភេទដីឡាបានសៀក និងប្រភេទដីកំពង់សៀម គឺមានភាពផុយស្រួយ មានគម្របដីស្រាប់ និងត្រូវការភ្ជួររាស់តិចតួច ឬក៏មិនភ្ជួររាស់តែម្តង ក្នុងការរៀបចំថ្នាលដំណាំ។ ក្នុងករណីនេះ ការភ្ជួររាស់មុនពេលដាំអាចត្រូវបានជំនួសដោយការប្រើថ្នាំសម្លាប់ស្មៅ ដូចជាខ្លៃផូសេត (glyphosate) ដែលអាចគ្រប់គ្រងរុក្ខជាតិចង្រៃ ដោយមិនធ្វើឱ្យបាត់សំណើមដី។ ការភ្ជួររាស់ដីក៏មិនសូវមានប្រសិទ្ធភាពផងដែរ ក្នុងការកំចាត់រុក្ខជាតិចង្រៃ នៅពេលដីមានភាពសើម ថ្នាំសម្លាប់ស្មៅអាចប្រើជំនួសនៅក្នុងល័ក្ខខ័ណ្ឌបែបនេះ។ ការរក្សាទុកកាកសំណល់ដំណាំនៅតាមចំការបន្ទាប់ពី ប្រមូលផលអាចជួយទប់មិនអោយរុក្ខជាតិចង្រៃ ដុះលូតលាស់បាន (រូបភាព៣)។

## ការឱ្យសត្វស៊ី ឬការដុតចោល

ការឱ្យសត្វស៊ីក្នុងបរិមាណច្រើន ឬការដុតចោល ជាញឹកញាប់ត្រូវបានប្រើដើម្បីគ្រប់គ្រងរុក្ខជាតិចង្រៃ និងធ្វើឱ្យមានភាពងាយស្រួលក្នុងការភ្ជួររាស់ដី (រូបភាព៤)។ ការអនុវត្តន៍បែបនេះធ្វើអោយខូចប្រយោជន៍ ដូចជាការកាត់បន្ថយគម្របដី សីតុណ្ហភាពដីស្រទាប់លើកើនឡើង និងសំណើមក្នុងដីថយចុះ។ ការដុតកាកសំណល់ដំណាំ ធ្វើឱ្យសារធាតុសរីរាង្គរបស់ដីថយចុះផងដែរ ដែលជាមូលហេតុធ្វើអោយដីខ្សោះជីជាតិ និងបង្កើនការហូរច្រោះ។ ការរក្សាទុកកាកសំណល់ដំណាំលើដីចំការ និងការបន្ថែមគម្របដី ដូចជាចំបើង អាចកាត់បន្ថយការដុះរបស់រុក្ខជាតិចង្រៃអាចជួយរក្សាសំណើមក្នុងដី និងបន្ថយសីតុណ្ហភាពក្នុងដី។



*រូបភាពទី៣: រុក្ខជាតិចង្រៃអាចយកទៅប្រើធ្វើជាគម្របគល់ដំណាំ។ នេះគឺជាការប្រើប្រាស់ស្មៅទន្សោង ធ្វើជាគម្របគល់ដំណាំកប្បាស។*



*រូបភាពទី៤ : កាកសំណល់ដំណាំគួរយកទៅដាក់ក្នុងចំការវិញ ជាជាងដុតបំផ្លាញចោល។ គម្របដីរក្សាសំណើមក្នុងដី និងកាត់បន្ថយការដុះលូតលាស់រុក្ខជាតិចង្រៃ។*

## រុក្ខជាតិចង្រៃសំខាន់ៗ

ក្នុងសៀវភៅនេះ មានរួមបញ្ចូលរុក្ខជាតិចំនួន៧០ប្រភេទដែលជួបប្រទះញឹកញាប់ក្នុងតំបន់ចម្ការដំណាំ។ មិនមែនគ្រប់រុក្ខជាតិទាំងនេះ ត្រូវបានចាត់ទុកថាជាប្រភេទរុក្ខជាតិចង្រៃខ្លាំងនៅក្នុងប្រព័ន្ធដាំដុះដំណាំចំការនាពេលថ្មីៗនេះទេ។ តែរុក្ខជាតិទាំងនេះមួយចំនួនមានសក្តានុពលក្លាយជារុក្ខជាតិចង្រៃ ក្រោមការផ្លាស់ប្តូរការអនុវត្តន៍ការដាំដុះដំណាំកសិកម្ម។ ឧទាហរណ៍ ការផ្លាស់ប្តូរការកាត់បន្ថយការភ្ជួររាស់ដី ឬការដាំដុះដំណាំ។ ឈ្មោះរុក្ខជាតិដែលមាននៅក្នុងតារាងទី១ ត្រូវបានចាត់ទុកថាជាប្រភេទរុក្ខជាតិចង្រៃសំខាន់បំផុតនៅក្នុងប្រព័ន្ធដាំដុះដំណាំចំការនាពេលថ្មីៗដែលផ្អែកលើការភ្ជួររាស់ដី និងការកំចាត់រុក្ខជាតិចង្រៃដោយដៃ។ រុក្ខជាតិចង្រៃទាំងនេះ ជាបញ្ហាមួយព្រោះវាអាចសំរបបានតាមលក្ខខ័ណ្ឌនៃការរៀបចំដី និងដីប្តូរទំរង់។ លក្ខខ័ណ្ឌទាំងនេះនៅលើដីដែលរៀបចំរួចសំរាប់ដាំដុះ និងដីដែលមានប្រតិកម្មបំបែកធាតុអាសូត ធ្វើឱ្យរុក្ខជាតិចង្រៃឯកវត្ស ដុះលូតលាស់យ៉ាងលឿន។ ប្រភេទរុក្ខជាតិចង្រៃដែលមានដើមក្រោមដី ឬមើម ដូចជា *ស្មៅក្រវាញជ្រូក (Cyperus rotundus)* គឺមានការលំបាកក្នុងការកំចាត់ ដោយវាអាចដុះឡើងវិញយ៉ាងឆាប់ បន្ទាប់ពីជម្រះដោយចប។ ប្រភេទរុក្ខជាតិដែលមានដើមក្រាសទន់ ដូចជា *ស្មៅស្លាបទា (Commelina benghalensis)* មានការលំបាកក្នុងការកំចាត់ផងដែរ ដោយសារដើមដែលកាត់នោះ ដុះឫសនិងលូតលាស់ឡើងវិញបានយ៉ាងឆាប់។

*តារាងទី១: រុក្ខជាតិចង្រៃសំខាន់ៗនៃប្រព័ន្ធដាំដុះដំណាំចំការក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន*

| ពួកស្មៅ និងកក់ | រុក្ខជាតិចង្រៃស្លឹកធំ |
|---|---|
| ស្មៅគោ *Brachiaria reptans*, Smao Ko | ផ្ទីបន្លា/ផ្ទីដូង *Amaranthus spp.*, Phti Banla, Phti Daung |
| ស្មៅចិញ្ចៀន *Cynodon dactylon*, Smao Chenh Chean | ផ្ទីថ្មឈ្មោល *Boerhavia diffusa*, Phti Thmar |
| ស្មៅក្រវាញជ្រូក *Cyperus rotundus*, Kravanh Chruk | មមាញខ្មោចលឿង *Cleome viscosa*, Momeanh Khmoch |
| ស្មៅជើងក្រាស់ *Dactyloctenium aegyptium*, Smao Cheung Kras | ស្មៅស្លាបទា *Commelina benghalensis*, Slab Tea |
| ស្មៅសំបុកមាន់ *Digitaria adscendens*, Smao Sambok Mon | ទឹកដោះខ្លាធំ *Euphorbia heterophylla*, Tuk Das Khla Thom |
| ស្មៅបែកក្បាលគ្មានកន្ទុយ *Echinochloa colona*, Smao Bek Kbal | ប៉េងប៉ោះស្រោម *Physalis angulata*, Pang Pos Srom |
| ស្មៅទន្សោង *Eleusine indica*, Smao Samsorng | ផ្ទីថ្មញី *Trianthema portulacastrum*, Chung Kong Proes |

# ការពិពណ៌នាអំពីរុក្ខជាតិចង្រៃ

## អត្តសញ្ញាណកម្ម នៃរុក្ខជាតិចង្រៃ

ប្រភេទរុក្ខជាតិចង្រៃ ឆ្លើយតបខុសគ្នាទៅនឹងរបៀបគ្រប់គ្រង ព្រោះវាមានវដ្តជីវិតតម្រូវការសារធាតុចិញ្ចឹម និងរបៀបបន្តពូជផ្សេងគ្នា។ វាឆ្លើយតបផ្សេងគ្នាផងដែរទៅនឹងការភ្ជួររាស់ដី និងឥទ្ធិពលថ្នាំសំលាប់ស្មៅ។ ដូច្នេះវាជាការសំខាន់សំរាប់អ្នកណែនាំ និងកសិករអាចកត់សំគាល់នូវប្រភេទរុក្ខជាតិចង្រៃផ្សេងគ្នា និងយល់ដឹងពីចំណុចខ្សោយរបស់វា។ សៀវភៅណែនាំនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង កំណត់អត្តសញ្ញាណប្រភេទរុក្ខជាតិចង្រៃ នៃដំណាំចម្ការក្នុងប្រទេសកម្ពុជា។

## សេចក្តីណែនាំអំពីការប្រើប្រាស់សៀវភៅនេះ

លំដាប់នៃការបង្ហាញប្រភេទរុក្ខជាតិនៅក្នុងសៀវភៅនេះ គឺរៀបទៅតាមលំដាប់លំដោយអក្ខរក្រម ដែលអាស្រ័យទៅតាមគ្រួសារ (អំបូរ) សន្តាន និងប្រភេទ។ គ្រួសាររបស់រុក្ខជាតិមួយ (ឧទាហរណ៍ គ្រួសារ Euphorbiaceae)) មានរុក្ខជាតិមួយចំនួនដែលមានលក្ខណៈសំគាល់រួមមួយ ឬច្រើន។ គ្រួសារនីមួយៗត្រូវបានចែកជាច្រើនសន្តានទៀតដូចជា *Chamaesyce*, *Euphorbia* និង *Jatropha* ជាដើម ដែលរុក្ខជាតិនៅក្នុងសន្តានជាមួយគ្នាមានលក្ខណៈសំគាល់រួមបន្ថែមទៀត។ សន្តាននីមួយៗ មានប្រភេទរុក្ខជាតិមួយ ឬច្រើន ដែលប្រភេទនីមួយៗមានលក្ខណៈសំគាល់ ឬឈ្មោះជាក់លាក់ផ្ទាល់ (ឧទាហរណ៍ ទឹកដោះខ្លាតូច (*Chamaesyce hirta*) ទឹកដោះខ្លាធំ (*Euphorbia heterophylla*) និងល្ហុងខ្វងក្រហម (*Jatropha gossypiifolia*) ជាដើម)។ ឈ្មោះរុក្ខជាតិទាំងនេះគឺខុសពីគ្នា និងខុសពីប្រភេទរុក្ខជាតិផ្សេងៗទៀត។ សៀវភៅណែនាំនេះ មានរួមបញ្ចូលឈ្មោះរុក្ខជាតិជាភាសាខ្មែរផងដែរ។

# ស្មៅគ្រាប់បែក - *Ruellia tuberosa* (Smao Krab Bek)



## របាយ

ដុះជាទូទៅតាមដងផ្លូវ និងដីទំនេរ នៅភាគពាយព្យ ក្នុងប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសមានរីសជាមើម។ ដើម: ឈរត្រង់ បែកមែកកំពស់ដល់ ៥០សង់ទីម៉ែត្រ។ ស្លឹក: ភាគច្រើននៅគល់ដើម មានរោមឆ្មារៗ រាងដូចស៊ុតស្រួចចុង ទៅទ្រវែងដែលមានទំហំ៤-៦ × ១,៥-២,៥ សង់ទីម៉ែត្រ។ ផ្កា: រាងជីឡាវពណ៌ស្វាយ បណ្តោយប្រវែង ៤-៦ សង់ទីម៉ែត្រ និងទទឹង ១២-១៥មីលីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនទំនងជារាលដាលទៅក្នុងចំការដំណាំទេ។

## ឯកសារយោង: ១

# ផ្ទីថ្មញី - *Trianthema portulacastrum* (Phti Thmar Nhi)



## របាយ

ដុះក្នុងល័ក្ខខ័ណ្ឌស្ងួត។ ដុះរាយប៉ាយក្នុងចំការដំណាំ តាមដងផ្លូវ និងដីទំនេរ ពាសពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស ឬពហុវត្ស។ ដើមៈ គ្របដី មានជាតិទឹក។ ស្លឹកៈ ពណ៌បៃតង រាងស៊ុតស្រួចចុង។ ផ្កាៈ តូចល្អិត ពណ៌សស៊ីជម្ពូរ បាំងដោយស្លឹក និងចេញផ្កាស្ទើរពេញមួយឆ្នាំ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះអាចចង្រៃខ្លាំង ក្នុងដំណាំចំការ។

## ឯកសារយោងៈ ២

# ស្មៅអណ្តាតគោ - *Achryanthes aspera* (Smao Andat Ko)



## របាយ

ឃើញមានតាមដីទំនេរ ដងផ្លូវ វាលស្មៅ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេស។ ដើម: ឈរត្រង់ កំពស់០,៥-២ ម៉ែត្រ។ ផ្កា: តូចល្អិត ពណ៌បៃតង។ ផ្លែ: មានបន្លាស្រោប ប្រវែង២,៥-២,៨មីលីម៉ែត្រ ងាយដាច់ចេញ។ ទ្រនាប់ផ្កាព័ទ្ធជុំវិញគ្រាប់សំយ៉ុងចុះក្រោម ងាយស្អិតជាប់នឹងសត្វ និងសំលៀកបំពាក់។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មាននៅតាមដងផ្លូវ ដីទំនេរ វាលស្មៅ ចំការដំណាំ (ពហុវត្ស) និងជួនកាលក្នុងដំណាំចំការ (ឯកវត្ស)។ ជាញឹកញាប់ ដុះរាលដាលតាមព្រៃចំការ។ អាចដុះលូតលាស់លើដីច្រើនប្រភេទ។

## ឯកសារយោង: ៣

# ស្មៅជើងបង្កង - *Alternanthera sessilis* (Smao Choeung Bangkang)



## របាយ

ឃើញមានច្រើនតាមមាត់អូរ មាត់ត្រពាំង ភ្លឺស្រែ ចង្អូរទឹករាក់ និងមាននៅក្នុងដំណាំចំការផងដែរ នៅរដូវភ្លៀង។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ឯកវត្ស ឬពហុវត្សអាយុខ្លី។ ដើម: ដុះវារ។ កញ្ចុំផ្កា: ប្រវែង៥_៧ សង់ទីម៉ែត្រ រាងមូល ឬទ្រវែង និងដុះចេញពីមុំគល់ស្លឹក។ ដុះរាលដាលដោយកំណាត់ដើមជាប់នឹងគ្រឿងយន្តដែលធ្លាក់ក្នុងភក់ និងដោយទឹកជំនន់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះតាមកន្លែងដែលមានសំណើមខ្ពស់ និងជាញឹញាប់ឃើញមាននៅក្បែរ និងក្នុងត្រពាំង ប្រឡាយ និងអាងទឹក។ អាចឃើញមានដុះតាមវាលភក់ ភ្លឺភ្លោះ/ប្រឡាយរាក់ៗ និងវាលស្រែទុកទំនេរ។ រុក្ខជាតិចង្រៃខ្លាំង ក្នុងស្រូវទំនាប និងស្រូវចំការ តែអាចមានដុះផងដែរក្នុងដំណាំចំការ។

## ឯកសារយោង: ២ និង ៣

# ផ្ទីបន្លា - *Amaranthus spinosus* (Phti Banla)



## របាយ

មានដុះក្នុងលក្ខខ័ណ្ឌស្ងួត និងឃើញមានតាមដងផ្លូវ ដីទំនេរ និងក្នុងដំណាំចំការ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

ឯកវត្សរ៍។ ដើម: ឈរត្រង់ មានបន្លាមុតស្រួចមួយគូរនៅតាមគល់ស្លឹកនីមួយៗ និងមានឆ្នូតពណ៌ក្រហម។ កញ្ចុំផ្កា: ពណ៌បៃតង។ សាយព្ជដោយគ្រាប់ ដែលអាចកប់ក្នុងដីបានយូរមិនខូច។ គ្រាប់រាលដាយដោយខ្យល់ និងទឹក។

## សារៈសំខាន់ក្នុងកសិកម្ម

លូតលាស់ល្អក្នុងចំការ នៅពេលដីមានសំណើមទាប និងមានដុះលើដីដែលសំបូរសារធាតុសរីរាង្គ និងធាតុអាសូតអាចស្រូបបាន។ ស្លឹកត្រូវបានយកធ្វើជាបន្លែ នៅប្រទេសកម្ពុជា។

## ឯកសារយោង: ២ និង ៧

# ផ្ទីដូង - *Amaranthus viridus* (Phti Daung)

## របាយ

មានដុះក្នុងល័ក្ខខ័ណ្ឌស្ងួត និងឃើញមាននៅតាមដីទំនេរ ដងផ្លូវ និងក្នុងដំណាំចំការ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: គ្របដី ទៅឈរត្រង់ បែកមែក កំពស់៣០-៨០សង់ទីម៉ែត្រ និងមានចង្អូរ អាចមានពណ៌ក្រហម។ ផ្កា: កួរ ពណ៌បៃតង ទៅស្វាយ ប្រវែង៥-១៥សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់ ។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះប្រជែងក្នុងដំណាំចំការ។ មានដុះលើដីច្រើនប្រភេទ និងលូតលាស់ល្អលើដីមានជីជាតិ។ ដំណុះគ្រាប់ត្រូវបានពន្លឿនដោយការប្រើជីអាសូត។ ស្លឹកប្រើធ្វើជាបន្លែ។

## ឯកសារយោង: ២ និង ៣



# ស្មៅសិរមាន់ព្រៃ/ផ្តីព្រះ - *Celosia argentea*
# (Smao Semann Prey/Phti Phresh)

## របាយ

មានដុះតាមដងផ្លូវ ដីទំនេរ ចំការកូនកៅស៊ូ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: ឈរត្រង់ បែកមែក រលោង រាងបំពង់រឹង និងកំពស់ដល់១៥០សង់ទីម៉ែត្រ។ ស្លឹក: វែង ស្តើងស្រួចចុង លើទងស្លឹកខ្លី។ កញ្ចុំផ្កា: ពណ៌ផ្កាឈូក។ ផ្លែ: រាងដូចស៊ុត។ គ្រាប់: ដូចគ្រាប់ភ្នែក ពណ៌ខ្មៅ និងប្រវែង១,៣-១,៥មីលីម៉ែត្រ។ សាយពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

បើមិនគ្រប់គ្រង រុក្ខជាតិនេះអាចប្រជែងខ្លាំងជាមួយដំណាំ ជាពិសេសសណ្តែកសៀង និងសណ្តែកបាយ។

## ឯកសារយោង: ១



# វល្លិ៍ត្រចៀកក្រាញ់ - *Centella asiatica* (Voir Tracheak Khranh)



## របាយ

មានដុះតាមដងផ្លូវ ដីទំនេរ និងក្នុងចំការដំណាំ។ ជួនកាលដុះតាមវាលស្មៅ និងទីប្លូវទំរង់ដែលមានពន្លឺថ្ងៃ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេស។ ដើម: ដុះវារ ប្រវែងជាទូទៅ១_១៥សង់ទីម៉ែត្រ។ ស្លឹក: រាងដូចបេះដូងមូលសំប៉ែត ឬដូចក្រលៀន គែមដូចធ្មេញ ប្រវែង២_៥សង់ទីម៉ែត្រ ធម្មតាមានទំហំធំ តែខ្លី។ ផ្កា: ប្រវែង១_៧សង់ទីម៉ែត្រ ក្នុងចង្កោមផ្កាតូច ដែលមានផ្កា២_៤ នៅជិតដី។ ស្រទាប់ផ្កា: ពណ៌ផ្កាឈូក_ស្វាយ ទទឹង១មីលីម៉ែត្រ កេសរឈ្មោលខ្លី។ ផ្លែ: ទទឹង៤_៥មីលីម៉ែត្រ និងកំពស់៣មីលីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

ជាទូទៅ ដុះក្នុងចំការដំណាំនៅខេត្តបាត់ដំបង តែជារុក្ខជាតិមិនប្រជែងខ្លាំងទេ។

## ឯកសារយោង: ១

# ទន្រ្ទានខេត្តស្វាយ - *Ageratum conzoides* (Tuntrean Kheth Svay)

## របាយ

ជាទូទៅ ឃើញមានដុះតាមចំការដំណាំ ពាសពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

តិណទេសឯកវស្ស។ ដើម: ឈរត្រង់ បែកមែក កំពស់ដល់១៨០ សង់ទីម៉ែត្រ។ ស្លឹក: ឈម មានរោមទន់ រាងស៊ុតស្រួចចុង ឬរាងបេះដូង ដែលមានគែមដូចធ្មេញរណា។ កញ្ចុំផ្កា: នៅផ្នែកខាងចុងដើម។ ផ្កា: ពណ៌ស ទៅស្វាយ។ សាយពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះក្នុងចំការដំណាំ តែមិនបង្កបញ្ហាធ្ងន់ធ្ងរទេ ក្នុងលក្ខខណ្ឌភ្ជួររាស់ដី។

## ឯកសារយោង: ២ និង ៧



# ទន្ទ្រានខេត្តស - *Chromolaena odorata* (Tuntrean Khet Sar)

## របាយ

មានដុះនៅលើដីដោះ ឬស្រស់ទឹកល្អ។ ឃើញមាននៅតាមដងផ្លូវ ដីទំនេរ វាលស្មៅ ចំការឈើហូបផ្លែ និងចំការដំណាំពហុវត្ស។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្សពហុវត្ស។ ដើមៈ កំពស់ដល់៣ម៉ែត្រ បែកមែក មានរោមមូល។ ស្លឹកៈ ឈម រាងស៊ុតស្រួចចុងត្រីកោណ មានរោម គែមដូចធ្មេញរណា ប្រវែង៨-១០សង់ទីម៉ែត្រ។ ផ្កាៈ ពណ៌ខៀវស្លេកនៅក្នុងចង្កោមផ្កា។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រាលដាលលើដីកាប់ឆ្ការរួច តែមិនអាចរស់បានទេបន្ទាប់ពីព្រៃ រឺដំណាំដុះគ្របពីលើ។ មិនមែនជារុក្ខជាតិចង្រៃសំខាន់ទេ ក្នុងការរៀបចំដីរឺក្នុងដំណាំឯកវត្ស។

## ឯកសារយោងៈ ២ និង ៧



# មុខឈ្នាង - *Eclipta alba* (Mok Chhneang)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌសើម និងស្ងួត។ ឃើញមាននៅតាមវាលស្រែ ចង្ហូរទឹក និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើមៈ ឈរត្រង់ រឺគ្របដី កំពស់ដល់៥០សង់ទីម៉ែត្រ។ ស្លឹកៈ ទោល ឈម រាងផ្លែលំពែង ទៅពងក្រពើ ស្មើរពេញមានរោមទាំងសងខាង។ ផ្កាៈ នៅលើមុំគល់ស្លឹក ឬចុងមែក មានអង្កត់ផ្ចិតប្រហែល១សង់ទីម៉ែត្រ ពណ៌ស ដែលមានត្របកផ្កាពណ៌បៃតងរាងជាបំពង់។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ជាទូទៅ ឃើញមាននៅទីដក់ទឹក។ មិនមែនជារុក្ខជាតិចង្រៃសំខាន់ក្នុងចំការដំណាំទេ។

## ឯកសារយោងៈ ២ និង ៧

# ដើមចំអេះ - *Spilanthes paniculata* (Deum Cham Eh)



## របាយ

មានដុះតាមដងផ្លូវ ដីទំនេរ នៅតំបន់ខ្ពស់។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស ឬពហុវស្ស។ ដើមៈ ទាប ដុះសន្ធឹងគ្របដី កំពស់០,៦-១,២ម៉ែត្រ ជួនកាលមានជាតិឈើនៅផ្នែកគល់ ជាញឹកញាប់ពណ៌ស្វាយ បែកមែក មានរោមរុយៗ។ ស្លឹកៈ ជាញឹកញាប់ពណ៌ខៀវខ្ចីប្រផេះពេលនៅស្រស់ ឆ្លាស់ រឺឈម មិនសូវក្រាស់ រាងទ្រវែង ទៅពងក្រពើ រឺ រាងស៊ុតស្រួចចុង ប្រវែង២-៩សង់ទីម៉ែត្រ និងទទឹង១,៥-៤សង់ទីម៉ែត្រ។ កញ្ចុំផ្កាៈ រឹងមាំ ប្រវែង១៥-៥០សង់ទីម៉ែត្រ និងអង្កត់ផ្ចិតដល់៧មីលីម៉ែត្រ។ ផ្កាៈ ពណ៌ខៀវស្លេក ប្រវែង៨-១១មីលីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

មិនត្រូវបានសង្កេតថា ជារុក្ខជាតិចង្រៃក្នុងដំណាំចំការទេ។

## ឯកសារយោងៈ ១

# ស្ពៃគោក - *Synedrella nodiflora* (Spey Kok)



## របាយ

រុក្ខជាតិចង្រៃដុះតាមចំការខ្ពស់ ដងផ្លូវ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើមៈ ឈរត្រង់ ស្ទើរស្មើជ្រុង កំពស់ដល់ ៩០សង់ទីម៉ែត្រ។ ស្លឹកៈ ឈម រាងពងក្រពើ រឺស៊ុតស្រួចចុងគែម ដូចធ្មេញមូល ឬធ្មេញរណា។ កញ្ចុំផ្កាៈ នៅលើមុំគល់ស្លឹកគ្មានទង ស្រទាប់ផ្កាពណ៌លឿង។ សាយពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះមានសក្តានុពលដុះប្រជែងជាមួយដំណាំចំការ បើមិនគ្រប់គ្រង។

## ឯកសារយោងៈ ១

# ស្មៅស្លឹករណា - *Tridax procumbens* (Smao Slek Rona)



## របាយ

មានដុះនៅក្នុងលក្ខខ័ណ្ឌតំបន់ខ្ពស់។ ដុះរាយប៉ាយក្នុងដំណាំចំការ តាមដងផ្លូវ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ឯកវស្ស ឬពហុវស្សអាយុខ្លី។ ដើមៈ ស្ទើរគ្របដី ប្រវែងដល់៥០ សង់ទីម៉ែត្រ។ រុក្ខជាតិចង្រៃដុះតាមវាលស្មៅ និងក្នុងដំណាំច្រើនប្រភេទ ឯកវស្ស ឬពហុវស្ស។ គ្រាប់ៈ រាលដាលទៅឆ្ងាយដោយសារខ្យល់។ បន្តពូជដោយគ្រាប់ ដើម និងឫស។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិប្រភេទស្លឹករណាឃើញមានដុះក្នុងចំការដំណាំ ជាញឹកញាប់អាចរស់បាននៅរដូវប្រាំង។ ជាទូទៅ ឃើញមានរុក្ខជាតិប្រភេទនេះដុះនៅដើមរដូវវស្សា តែត្រូវគ្រប់គ្រងដោយការភ្ជួររាស់ក្នុងប្រព័ន្ធដាំដុះប្រចាំឆ្នាំ។

## ឯកសារយោងៈ ២ និង ៣

# ឥសីផ្សំស្រេច - *Vernonia cinerea* (Ey Sei Phsom Srech)

## របាយ

ឃើញមានដុះនៅតាមចំការដំណាំ ដីទំនេរ និងដងផ្លូវ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើម: ឈរត្រង់ បែកមែក មានរោមកំពស់ដល់ ៨០សង់ទីម៉ែត្រ។ ស្លឹក: រាងស៊ុតស្រួចចុង ទៅរាងស៊ុតស្រួចគល់ មានរោមផ្នែកខាងក្រោម ទទឹង១-២, ៥សង់ទីម៉ែត្រ និងបណ្តោយ ២-៤សង់ទីម៉ែត្រ។ កញ្ចុំផ្កា: បែកមែកច្រើន។ ផ្កា: មានចំនួនច្រើន ពណ៌ស្វាយ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនបង្កបញ្ហាធ្ងន់ធ្ងរ ក្នុងប្រព័ន្ធដាំដុះដំណាំចំការទេ។

## ឯកសារយោង: ២



# ស្មៅប្រមោយដំរី - *Heliotropium indicum*
# (Smao Pramoy Damrey)



## របាយ

ជាទូទៅ ឃើញមានដុះនៅតាមដីទំនេរ និងជងផ្លូវ។ មិនឃើញមានដុះជាទូទៅនៅក្នុងចំការដំណាំទេ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្សា។ ដើមៈ បែកមែក មានរោមរុយៗ កំពស់១៥-៥០សង់ទីម៉ែត្រ។ ស្លឹកៈ រាងស៊ុតស្រួចចុង ប្រវែង៥-៧សង់ទីម៉ែត្រ។ ផ្កាៈ កួរ ប្រវែង៥-១៥សង់ទីម៉ែត្រ កោងផ្នែកខាងចុង។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនរំខានដល់ប្រព័ន្ធដាំដុះដំណាំចំការទេ។

## ឯកសារយោងៈ ២ និង ៧

# មមាញស្រុក - *Cleome gynandra* (Momeanh Srok)



## របាយ

មានដុះនៅតាមទីស្ងួត ជាពិសេសតាមដងផ្លូវ វាលស្មៅ និងមានវត្តមានក្នុងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើមៈ កំពស់០,៥-១,៥ម៉ែត្រ មិនបែកមែកទៅបែកមែកមួយៗ មានរោមដែលរោមនីមួយៗ មានពកមូលនៅខាងចុង។ ស្លឹកៈ ៣-៧កូនស្លឹករាងផ្លែលំពែងស្រួចគល់ទៅរាងត្បូងពេជ្រ ប្រវែង២-៧,៥សង់ទីម៉ែត្រ និងទទឹង១-៣,៨សង់ទីម៉ែត្រ គែមដូចធ្មេញរណាតូចៗ ទៅរាងធ្មេញល្អិត ទងស្លឹកប្រវែង៣-៩សង់ទីម៉ែត្រ។ ផ្កាៈ ចង្កោមមានស្លឹករួមបីនៅខាងក្រោម ទ្រនាប់ផ្កាគ្មានទង ស្រទាប់ផ្កាពណ៌ស ប្រវែង១-២សង់ទីម៉ែត្រ ដែលមានដង្កៀបវែង។ ផ្លែៈ គ្មានសាច់ រាងបំពង់តូចប្រវែង៣-១១សង់ទីម៉ែត្រ អង្កត់ផ្ចិត៤-៥មីលីម៉ែត្រ មានគ្រាប់ច្រើន ។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅក្នុងចំការដំណាំ តែមិនប្រជែងខ្លាំងជាមួយដំណាំទេ។

## ឯកសារយោងៈ ១

# មមាញខ្មោចក្រហម - *Cleome rutidosperma* (Momeanh Khmoch Kraharm)

## របាយ

មានដុះនៅតាមចំការដំណាំ ដងផ្លូវ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើមៈ ជ្រុង កំពស់ដល់១ម៉ែត្រ មានរោមទន់ពាសពេញ។ ស្លឹកៈ កូនស្លឹក៣ រាងស៊ុតស្រួចចុង ទៅរាងផ្លែលំពែង(ប្រវែង២-៥សង់ទីម៉ែត្រ)។ ផ្កាៈ ទោល នៅលើមុំគល់ស្លឹកពណ៌ក្រហម ប្រែផ្កាឈូកពេលចាស់ ស្រទាប់ផ្កា ៤ ប្រវែង៩-១២មីលីម៉ែត្រ នៅផ្នែកខាងលើ។ សាយពូជដោយគ្រាប់ ទឹក គ្រឿងយន្តកសិកម្ម និងស្រមោច។

## សារៈសំខាន់ក្នុងកសិកម្ម

វាជាប្រភេទរុក្ខជាតិចង្រៃរបស់ដំណាំចំការ និងបរិស្ថានផងដែរ។ វាផ្សាំនឹងធាតុអាកាស ក្នុងតំបន់អាស៊ីអាគ្នេយ៍។ វាលូតលាស់យ៉ាងរហ័ស ដែលត្រូវកំចាត់ចេញពីដំណាំ។ ថ្នាំសំលាប់ស្មៅជាច្រើនប្រភេទ ដែលបាញ់លើដី និងស្លឹក មានប្រសិទ្ធភាពលើរុក្ខជាតិប្រភេទនេះ។

## ឯកសារយោងៈ ៦



# មមាញខ្មោចលឿង - *Cleome viscosa* (Momeanh Khmaoch Loeung)



## របាយ

ឃើញមានដុះនៅតាមវាលស្រែ ព្រមទាំងតាមចំការដំណាំ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើម: ឈរត្រង់ កំពស់២០-១៤០សង់ទីម៉ែត្រ។ ស្លឹក: កូនស្លឹក៣ រឺ៥ ។ ផ្កា: ពណ៌លឿង ដែលមានស្រទាប់ផ្កា ៤។ ផ្លែ: កូរ ស្រដៀងផ្លែសណ្តែក រាងស្តួច និងមានប្រវែង៣-៤ សង់ទីម៉ែត្រ។ សាយពូជដោយគ្រាប់ស្អិត។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅក្នុងចំការដែលមានដាំដំណាំ និងតាមដងផ្លូវ។ នៅប្រទេសកម្ពុជា រុក្ខជាតិនេះត្រូវបានស្គាល់ថា: ជា "បន្លែខ្មោច" ដោយសារវាដុះលើផ្នូរខ្មោច។

## ឯកសារយោង: ១១

# ស្មៅចំពុះទា - *Cyanotis axillaris* (Smao Champus Tea)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌសើម។ ឃើញមានដុះនៅតាមវាលស្រែ និងចង្ហូរទឹក។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើមៈ មានជាតិទឹក វារតោងឡើង និងដុះឫសចេញពីថ្នាំងផ្នែកខាងក្រោម។ ស្លឹកៈ រាងផ្លែលំពែងត្រង់ ដែលមានស្រទបស្លឹករាងជាបំពង់មានរោម។ ផ្កាៈ ទោល នៅលើមុំគល់ស្លឹក ដែលមានស្រទាប់ផ្កា៣ ពណ៌ស្វាយ ទៅស្វាយចាស់។ បន្តពូជក្នុងដំណាក់កាលលូតលាស់ និងដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

វាជារុក្ខជាតិតូច ដែលដុះសន្ធឹង វារតាមដីចំការផ្នែកដែលទាប។

## ឯកសារយោងៈ ២

# ស្មៅស្លាបទា _ *Commelina benghalensis* (Smao Slab Tea)

## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌមានសំណើម។ មានដុះនៅក្នុងដំណាំចំការនៅប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស ឬពហុវត្ស។ ដើម: វល្លិ៍ ក្រាស់ទន់ វារគ្របដីមានរោម បែកមែកប្រវែង៣០_៥០សង់ទីម៉ែត្រ និងមានឫសដុះចេញតាមថ្នាំង។ ផ្កា: ពណ៌ស្វាយចាស់ ទៅខៀវ។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះដុះវារគ្របដី មានឫសជាស្រេចតាមថ្នាំង ដែលធ្វើអោយវាជារុក្ខជាតិចង្រៃខ្លាំងក្នុងការដាំដុះដំណាំ។ វាមានជាតិទឹកខ្ពស់ និងមានតម្លៃតិចតួចសំរាប់ធ្វើជាចំណីសត្វ តែត្រូវបានយកធ្វើចំណីជ្រូកក្នុងប្រទេសកម្ពុជា។

## ឯកសារយោង: ២ ៣ និង ៧



# ដើមផ្កាកណ្ដឹងគោ - *Ipomoea cairica* (Deum Phcar Kandeung Ko)

## របាយ

ឃើញមានដុះនៅតាមកន្លែងស៊ុបទ្រុប ដងផ្លូវ ដីទំនេរ និងទីដែលដាំដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើមៈ រុំព័ទ្ធ មានឫសមើម ប្រវែងដល់៥ម៉ែត្រ។ ស្លឹកៈ រាងដូចបាទដៃឆែកជា៥ ដល់គល់ស្លឹក។ កញ្ចុំផ្កាៈ មានផ្កា១ វីច្រើន។ ស្រទាប់ផ្កាៈ ពណ៌ផ្កាឈូក ស្វាយ ឬក្រហមស្វាយដែលផ្នែកកណ្ដាលមានពណ៌ចាស់ជាង និងកម្រមានពណ៌សណាស់។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

កម្រឃើញមានដុះនៅក្នុងចំការដំណាំណាស់។

## ឯកសារយោងៈ ៨



# វល្លិ៍មួយលិប _ *Ipomoea obscura* (Voir Mouy Lib)



## របាយ

ឃើញមានដុះនៅក្នុងដំណាំចំការ វាលស្មៅ ដងផ្លូវ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស ឬពហុវស្ស។ ដើមៈ រុំព័ទ្ធ ប្រវែង១_៣ម៉ែត្រ កំរាស់ប្រហែល៣មីលីម៉ែត្រ។ ស្លឹកៈ រាងដូចបេះដូងប្រវែង៤_៨សង់ទីម៉ែត្រ។ ប្រភេទជាច្រើនរបស់ អ៊ីប៉ូម៉ូអា *(Ipomoea)* ដាក់គ្រាប់នៅក្នុងផ្លែគ្មានសាច់រាងមូល។ គ្រាប់រាលដាលដោយខ្យល់ និងទំងន់គ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ប្រភេទរុក្ខជាតិនេះ ជាទូទៅដុះតាមដងផ្លូវ និងព្រៃចំការ។ តែវាមិនបង្ករបញ្ហាធ្ងន់ធ្ងរដល់ដំណាំចំការដូចដើមសណ្ដាជូ *(I. triloba)* ទេ។

## ឯកសារយោងៈ ៨

# ដើមសណ្តាជូ - *Ipomoea triloba* (Deum Sandar Chou)



## របាយ

ឃើញមានដុះនៅក្នុងដំណាំចំការ វាលស្មៅ ដងផ្លូវ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើមៈ រុំព័ទ្ធ ប្រវែង១-៣ម៉ែត្រ មានកំរាស់ប្រហែល៣មីលីម៉ែត្រ។ ស្លឹកៈ គែមមានជ្រុង៣ និងមានប្រវែង៤-១១សង់ទីម៉ែត្រ។ ផ្កាៈ រាងជីឡាវ គែមស្រទាប់ផ្កាមានជ្រុង៥ ពណ៌ផ្កាឈូក ឬក្រហមស្លេក និងខ្ទិបបិទក្រោយថ្ងៃត្រង់។ ស្គាល់តិចតួចពីជីវសាស្ត្ររបស់រុក្ខជាតិនេះ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

វាអាចលូតលាស់ ក្នុងពេលជាមួយគ្នានៃដំណាក់កាលលូតលាស់របស់ដំណាំចំការរបស់កសិករ និងអាចដុះគ្របដំណាំ។ វាត្រូវបានកត់សំគាល់ថាជារុក្ខជាតិចង្រៃលើដំណាំពោត សណ្តែកដី ស្រូវចំការ និងអំពៅ។

## ឯកសារយោងៈ ៣ និង ៨

# ស្លឹកបាស - *Trichosanthes cucumerina* (Sleuk Bash)



## របាយ

មានដុះនៅតាមជងផ្លូវ ដីទំនេរ និងព្រៃចំការ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេស។ ដើមៈ វល្លិ៍ វារតោងឡើង ប្រវែង៥-៦ម៉ែត្រ ពណ៌បៃតង ៤ជ្រុង និងមានរោម។ ស្លឹកៈ មានរោមលើផ្ទៃទាំងសងខាង រាងមូល ប្រវែង៧-១៤សង់ទីម៉ែត្រ ធំទូលាយ គែមមានជ្រុង៣-៥ និងផ្នែកខាងគល់រាងបេះដូងរីកធំ។ បញ្ចុំផ្កាឈ្មោលៈ មានផ្កា ៦-១៥ និងស្រទាប់ផ្កាៈ ពណ៌ស ប្រវែងប្រហែល១,៣ សង់ទីម៉ែត្រ។ កញ្ចុំផ្កាញីៈ ទោល នៅលើម៉ុំគល់ស្លឹក។ ផ្លែៈ រាងពងក្រពើ ប្រវែង៣-៤,៥ សង់ទីម៉ែត្រ និងអង្កត់ផ្ចិត ២,៥-៣សង់ទីម៉ែត្រ ពណ៌បៃតង និងចំរុះពណ៌ ដែលមានស្នាមឆ្នូតតាមបណ្តោយផ្លែពណ៌ប្រផេះពេលនៅខ្ចី និងពណ៌ទឹកក្រូចក្រហមពេលទុំ។

## សារៈសំខាន់ក្នុងកសិកម្ម

មិនចង្រៃខ្លាំងទេ ក្នុងប្រព័ន្ធដាំដុះដំណាំចំការ។

**ឯកសារយោងៈ ១២**

# ស្មៅក្រវាញជ្រូក - *Cyperus rotundus* (Smao Kravanh Chruk)



## របាយ

មានដុះនៅក្នុងលក្ខខ័ណ្ឌស្ងួត។ ដុះលូតលាស់តាមដីទំនេរ ចំការដំណាំ និងធន់នឹងដីមានសំណើមផងដែរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

តិណទេសពហុវត្ស។ ដើមៈ មានមើម និងខ្នែង កំពស់៣០_៧០ សង់ទីម៉ែត្រ។ ស្លឹកៈ ប្រវែង៥_២០សង់ទីម៉ែត្រ។
កញ្ចុំផ្កាៈ មានចំនួន៣_៨ប្រវែងមិនស្មើគ្នា។
កន្សោមផ្កាៈ សំប៉ែត គ្មានទង ប្រវែង១_៣សង់ទីម៉ែត្រ។ មើមៈ ជាប់គ្នាបង្កើតជាច្រវាក់មើម ទំហំដល់២៥មីលីម៉ែត្រ ដែលមានពន្លកបណ្តូល និងឫស។

## សារៈសំខាន់ក្នុងកសិកម្ម

ទោះជាមានដើមតូច ស្មៅក្រវាញជ្រូក ដុះប្រជែងយ៉ាងខ្លាំង ជាមួយដំណាំចំការ។ តែវាមិនធន់នឹងម្លប់ និងអាចលូតលាស់យឺត បើប្រើថ្នាំ២,៤_ឌី (2,4-D) ក្នុងវាលស្មៅ ឬប្រើដំណាំគម្រប

## ឯកសារយោងៈ ២ និង ៧

# ស្មៅពុកមាត់ឆ្មា - *Acalypha indica*
# (Smao Pokmaot Chhmar)



## របាយ

ឃើញមានដុះនៅតាមដងផ្លូវ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើមៈ មានកំពស់ដល់៥០សង់ទីម៉ែត្រ។ ការប៉ះពាល់រុក្ខរស ឬជ័រនៃប្រភេទរុក្ខជាតិ ក្នុងគ្រួសារមាន ជ័រល្វីងនេះ អាចធ្វើអោយរលាកស្បែកធ្ងន់ធ្ងរ។

## សារៈសំខាន់ក្នុងកសិកម្ម

មិនត្រូវបានគិតថា ជារុក្ខជាតិចង្រៃខ្លាំងក្នុងប្រព័ន្ធដាំដុះដំណាំចំការទេ។

## ឯកសារយោងៈ ១៣

# ទឹកដោះខ្លាតូច - *Chamaesyce hirta* (Tuk Das Khla Touch)



## របាយ

មានដុះនៅតាមដងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ជួនកាល ត្រូវបានយកធ្វើជាឱសថ។ លក្ខណៈពិសេស គឺដើមមានជ័រដូចទឹកដោះ និងជួនកាលស្លឹកមានស្នាមពណ៌ស្វាយ ដែលមានគែមដូចធ្មេញ។ ស្លឹក: ឈម គែមរាងដូចធ្មេញ ប្រវែង១-៥ សង់ទីម៉ែត្រ និងទទឹង០,៥-២,៥សង់ទីម៉ែត្រ។ គ្រាប់: អាចបង្កើតបានក្នុងរយៈពេលមួយខែ ឬខ្លីជាងនេះ និងចំនួនដើមជាច្រើនអាចដុះលូតលាស់ក្នុងរយៈពេលដ៏ខ្លី។ ផ្កា: មានពេញមួយឆ្នាំ។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះរាលដាលជាដំបូងលើដីទំនេរ ពិសេសក្នុងលក្ខខ័ណ្ឌសើម រឺស្រោចស្រព។ រុក្ខជាតិមានជាតិពុលតិចតួច និងត្រូវចាត់ទុកថាគ្មានប្រយោជន៍សំរាប់ចំណីសត្វ។

**ឯកសារយោង: ២ ៣ និង ៧**

# ទឹកដោះខ្លាធំ - *Euphorbia heterophylla* (Tuk Das Khla Thom)

## របាយ

ឃើញមានដុះនៅតាមចំការដំណាំ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ឯកវត្ស។ ដើម: មានជ័រ មូល ប្រហោងក្នុង បែកចំពាមបន្តបន្ទាប់នៅខាងចុង។ ស្លឹក: ប្រវែង៥-១០សង់ទីម៉ែត្រ ពណ៌សផ្នែកខាងក្រោម។ ផ្លែ: មានជ្រុង៣ គ្មានសាច់ អង្កត់ផ្ចិត៣,៥-៥,០ មីលីម៉ែត្រ។ រុក្ខជាតិនេះមានវដ្តជីវិតខ្លី អាចដុះលូតលាស់បាន៤ជំនាន់ក្នុងមួយឆ្នាំ។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះលូតលាស់លើដីច្រើនប្រភេទ ភាគច្រើនដុះនៅរដូវវស្សា។ វាជាញឹកញាប់រាលដាលពេញ ក្នុងចំការដំណាំពហុវត្សកប្បាស សណ្តែកសៀង និងពោត។

## ឯកសារយោង: ២ និង ៣



# ទឹកដោះខ្លាក្រហម - *Euphorbia thymifolia* (Tuk Das Khla Kraharm)



## របាយ

ឃើញមានដុះនៅតាមដងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស។ ដើម: បែកមែកសន្ធឹងគ្របដី មានរោម និងពណ៌ក្រហម។
ស្លឹក: ស្និត (២ជួរឈមគ្នា)។ ផ្កា: នៅលើមុំ
គល់ស្លឹកពណ៌ផ្កាឈូក ទៅស្វាយ។ ផ្លែ: គ្មានសាច់ ដែលមានរោម
រាងត្រីកោណ ពណ៌បៃតង។ មានជ័រដូចទឹកដោះគោ។
បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅតាមចំការដំណាំ តែមិនទំនងជារុក្ខជាតិដុះប្រជែង ជាមួយដំណាំទេ។

## ឯកសារយោង: ២

# ល្ហុងខ្វង - *Jatropha curcas* (Lhong Kvarng)



## របាយ

ដុះជាទូទៅនៅតាមដងផ្លូវ របង និងព្រៃចំការ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ដើម: ឈើតូច កំពស់ដល់៥ម៉ែត្រ។ ស្លឹក: ទុំជ្រុះ រាងស៊ុតស្រួចចុងធំទូលាយ ទៅរាងបេះដូង ទំហំ២៥ × ១៥សង់ទីម៉ែត្រ តែមានជ្រុង៣-៥ ទងស្លឹកប្រវែងដល់១៥សង់ទីម៉ែត្រ។ ផ្កា: ចង្កោមនៅចុងដើម។ កញ្ចុំត្របកផ្កាឈ្មោល: តែមមានជ្រុង៥ ប្រវែង៤មីលីម៉ែត្រ ត្របកផ្កា៥ប្រវែង៦មីលីម៉ែត្រ ពណ៌បៃតងស្លេក ទៅលឿងស កេសឈ្មោល៨-១០។ កញ្ចុំត្របកផ្កាញី: តែមមានជ្រុង៥ ប្រវែង៦-៩ មីលីម៉ែត្រ ត្របកផ្កាញីស្រដៀងនឹងត្របកផ្កាឈ្មោលដែរ បំពង់កេសរញីបែកជាពីរនៅផ្នែកខាងចុង។ ផ្លែ: រាងស៊ុត មានទំហំ៤ × ៣មីលីម៉ែត្រ ទុំមានពណ៌លឿង ពេលទុំស្ងួតមានពណ៌ត្នោត និងប្រេះបែក។ គ្រាប់: មានបីពណ៌ខ្មៅ រាងស៊ុត ទំហំ២០ × ១២ × ៩ មីលីម៉ែត្រ និងមានផ្ទៃរឹងគ្រើម។

## សារៈសំខាន់ក្នុងកសិកម្ម

ដាំធ្វើជារបងរស់ ការពារសត្វ និងផ្តល់ជាម្លប់។ គ្រាប់មានរស់ជាតិតែមានផ្ទុកប្រេងម្យ៉ាងដែលធ្វើឱ្យក្អួតចង្អោរ និងរាគ។ រុក្ខជាតិប្រភេទនេះមានសក្តានុពល សម្រាប់ផលិតកម្មជីវឥន្ធនៈនៅប្រទេសកម្ពុជា។

**ឯកសារយោង: ១០**

# ល្ហុងខ្វងក្រហម - *Jatropha gossypiifolia* (Lhong Kvarng Kraharm)



## របាយ

មានដុះនៅតាមជងផ្លូវ របង និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្ស។ ដើម: កំពស់ប្រហែល ១,៥ ម៉ែត្រ។ ស្លឹក: ស្ដើង គែមឆែក (មានជ្រុង) ៣-៥ ពណ៌ស្វាយ ដូចធ្មេញរណាតូចៗ ប្រវែងប្រហែល១០សង់ទីម៉ែត្រ និងមានទទឹងទូលាយ រឺធំជាងនេះ។ ផ្កា: ពណ៌ក្រហមចាស់ អូវវ៉ែ ទំហំ១សង់ទីម៉ែត្រ គ្មានត្របកផ្កា គែមមានជ្រុងនៅជុំវិញផ្ចិតនៃកញ្ចុំផ្កា។ ផ្លែ: រាងទ្រវែង មានជ្រុង ២-៣ ពណ៌ត្នោតពេលទុំ ប្រវែងប្រហែល១,៣សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះបង្កើតបានជាគុម្ពស៊ុបទ្រប់។ ប្រែប្រួលទៅតាមកន្លែងជាច្រើន។ ជាញឹកញាប់ដាំធ្វើជារុក្ខជាតិលំអរ។ គ្រាប់ពុលដល់មនុស្ស។ អាចជារុក្ខជាតិចង្រៃដោយធ្វើឱ្យខូចដល់វាលស្មៅ និងមាត់ទន្លេដែលមានដីប្លូរទំរង់។

## ឯកសារយោង: ៩

# ស្មៅប្រក់ផ្លែ - *Phyllanthus niruri* (Smao Brork Phlair)



## របាយ

ដុះតាមចំការដំណាំ ដីទំនេរ និងដងផ្លូវ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: តូច ឈរត្រង់កំពស់៣០-៤០សង់ទីម៉ែត្រ។ ស្លឹក: ស្មិត កូនស្លឹករាងទ្រវែង ដុះពេញគ្មានទង។ ផ្កា: មានទងខ្លី ដុះចេញពីគល់ស្លឹក និងមានពណ៌ស ឬបៃតងស្លេក។ ផ្លែ: គ្មានសាច់ មូលរលោង។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ទោះជាមានដុះតាមចំការ តែវាមិនប្រជែងខ្លាំងជាមួយដំណាំចំការទេ។

## ឯកសារយោង: ២ និង ៣

# ស្មៅអំបោះ - *Aeschynomene americana* (Smao Ambosh)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌស្ងួត។ ឃើញមានដុះតាមចំការដំណាំ ដីទំនេរ និងវាលស្មៅ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្សពហុវស្ស។ ដើម: ឈរត្រង់ បែកមែក មានរោម។ ស្លឹក: ស្មិតរួម ដែលកូនស្លឹករាងទ្រវែង ប្រវែង៧-១០ មីលីម៉ែត្រ។ ផ្កា: ពណ៌ផ្កាឈូក ដែលមានពណ៌ក្រហមនៅចំកណ្តាលលើចង្កោមផ្កា។ ផ្លែ: កួរដូចពួកផ្លែសណ្តែករាងទ្រវែង កោង ប្រវែង២-៣សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនជារុក្ខជាតិចង្រៃខ្លាំង ក្នុងចំការដំណាំទេ។

## ឯកសារយោង: ២

# ដើមសន្ទះឱម៉ាល់ - *Alysicarpus monilifer* (Deum Santeah Omal)

## របាយ

ដុះតាមដងផ្លូវ ដីវាលស្មៅ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស រឺពហុវត្ស។ ដើមៈ ដុះលូតលាស់ឃឹត បែកមែក កំពស់៥-១៥សង់ទីម៉ែត្រ។ ស្លឹកៈ ទោល រាងស៊ុតស្រួចចុង ពងក្រពើ រឺផ្លែលំពែង រាងបេះដូងនៅគល់ស្លឹកប្រវែង២,៥-៧,៥សង់ទីម៉ែត្រ មានរោមនៅផ្ទៃស្លឹកខាងក្រោម។ កញ្ចុំផ្កាៈ ប្រវែង១-១៥សង់ទីម៉ែត្រ ផ្កាពណ៌ក្រហម។ ផ្លែៈ ក្លូវជាប់គ្នា៣-៥ ប្រវែង១-២សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ដាំធ្វើជាចំណីសត្វ។ អាចជាធាតុមួយមានប្រយោជន៍សំរាប់វាលស្មៅ ក្នុងរយៈពេលខ្លី និងវែង ក្នុងតំបន់ដែលមានរបបទឹកភ្លៀងតិច ទៅមធ្យម ពិសេសវាលស្មៅដែលញាំញីដោយសត្វច្រើន។

## ឯកសារយោងៈ ៤



# សណ្ដែកខ្មោច - *Cassia occidentalis* (Sandek Khmoch)



## របាយ

មានដុះនៅតាមដងផ្លូវ ដីទំនេរ កន្លែងកប់ខ្មោច និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្សរ។ ដើម: ឈរត្រង់ កំពស់ដល់២ម៉ែត្រ។
ស្លឹក: រួម ផ្ទៃស្លឹកដូចស្បែក រាងស៊ុតស្រួចចុង។ ផ្កា: ពណ៌លឿង។
ផ្លែ: កួរ ពណ៌ត្នោតចាស់ និងកោងឡើងលើបន្តិច។
គ្រាប់: ពណ៌ត្នោតចាស់ និងសំប៉ែតចុងទាំងសងខាង។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅតាមតំបន់ខ្ពស់ តែមិនចង្រៃខ្លាំងក្នុងការដាំដុះដំណាំឯកវត្សរឡើយ។

## ឯកសារយោង: ១

# ដង្ហិតឈ្នាង រឺដង្ហិតខ្មោច - *Cassia tora* (Danghet Chhneang, Danget Khmoch)



## របាយ

មានដុះនៅតាមដងផ្លូវ ដីទំនេរ កន្លែងកប់ខ្មោច និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

តិណទេសឯកវស្ស។ ដើមៈ ពាក់កណ្តាលឈើ ឈរត្រង់ កំពស់ ០,៥-១,៥ម៉ែត្រ ដែលមានឫសកែវយ៉ាងរឹងមាំ។ ស្លឹកៈ រូមប្រវែង៨-១២សង់ទីម៉ែត្រ ដែលមានកូនស្លឹកប្រវែង២-៤សង់ទីម៉ែត្រ។ គ្រាប់ៈ ដុះ និងរស់បាននៅក្រោមល័ក្ខខ័ណ្ឌជាច្រើន។ ដូចពូកសណ្តែកផ្សេងៗទៀតដែរ សំបកគ្រាប់អាចការពារមិនអោយទឹកជ្រាបចូល និងដំណុះគ្រាប់អាចត្រូវបានជម្រុញដោយបកសំបកចេញ។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅតាមវាលស្មៅ ដងផ្លូវ ដីទំនេរ និងចំការដំណាំ។ ដុះលូតលាស់លើដីច្រើនប្រភេទ ក្នុងល័ក្ខខ័ណ្ឌទឹកភ្លៀងប្រហែល ១៥០០មីលីម៉ែត្រ និងមានដុះលើប្រភេទដីឥដ្ឋ។

## ឯកសារយោងៈ ៣

# វល្លិ៍កន្ទួយ _ *Centrosema pubescens* (Voir Kantouy)

## របាយ

មានដុះនៅតាមជងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសវល្លិ៍ពហុវត្ស។ ដើម: វារតោងឡើង ដែលមានដុះឫស តាមថ្នាំង។ ស្លឹក: រូមបី កូនស្លឹកមានរាងស៊ុតស្រួចចុង ទៅមូល សំប៉ែតប្រវែង៣សង់ទីម៉ែត្រ ទទឹង១,៣_២សង់ទីម៉ែត្រ ដែលមាន ចុងស្រួច និងមានរោមល្អិតៗ។ ផ្កា: ៣_៥ ពណ៌ស៊ីជម្ពូស្វាយស្លេក ទៅខៀវស្វាយ ផ្កាចង្កោមនៅលើម៉ុំគល់ស្លឹក។ ផ្លែ: កួរ ប្រវែង ១៣សង់ទីម៉ែត្រ និងទទឹង៥_៦មីលីម៉ែត្រ កោងបន្តិចដូចចំពុះដែល មានគ្រាប់ដល់១៥។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅតាមវាលស្មៅ លាយឡំជាមួយស្មៅដទៃទៀតសំរាប់ ច្រូតកាត់ធ្វើជាចំណីសត្វ។ មានសក្តានុពលធ្វើគម្របដីផងដែរ។ ដុះតិចតួចក្នុងដំណាំចំការ។

## ឯកសារយោង: ៤



# ស្មៅអញ្ចូន _ *Clitoria ternatea* (Smao Anhchaonn)

## របាយ

ដុះតាមដងផ្លូវ វាលស្មៅ និងព្រៃចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្សប្រភេទសណ្តែក។ ដើមៈ រឹងមាំ វារវ៉ុំព័ទ្ធមានរោមរ៉ុយៗ ប្រវែង០,៥_៣ម៉ែត្រ។ ស្លឹកៈ ស្និត មានកូនស្លឹក៥_៧។ ផ្កាៈ នៅលើម៉ុគល់ស្លឹក ផ្កាគូ វីទោល ប្រែប្រួលពីពណ៌សស្វាយស្វេក ខៀវខ្ចី ទៅខៀវចាស់។ ផ្លែៈ កូរត្រង់ទ្រវែងសំប៉ែត ប្រវែង៤_១៣ សង់ទីម៉ែត្រ និងទទឹង០,៨_១,២សង់ទីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

ដាំតាមវាលស្មៅ សំរាប់រយៈពេលខ្លី និងមធ្យម ប្រើធ្វើជាជីបៃតង និងគម្របដីសំរាប់ដំណាំ។ អាចបង្កើនជីជាតិដី និងទិន្នផលដំណាំដែលដាំក្រោយពីការដាំដំណាំជីបៃតងនេះ។ អាចដាំសំរាប់ច្រូតកាត់ធ្វើជាចំណីសត្វផងដែរ។

## ឯកសារយោងៈ ៤



# ស្មៅចង្ក្រងស្វា - *Crotalaria striata* (Smao Changkrang Svar)



## របាយ

ឃើញមានដុះជាទូទៅតាមដីទំនេរ និងផងផ្លូវ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: ឈរត្រង់ បែកមែក កំពស់៨០-១០០សង់ទីម៉ែត្រ។ ស្លឹក: រូមបី រាងស៊ុតមូល មានទងវែង។ ផ្កា: នៅចុងដើម ប្រវែង១០-២០សង់ទីម៉ែត្រ។ ផ្កា: ពណ៌លឿង និងបំពង់ទឹកដមពណ៌ស្វាយ។ ផ្លែ: កួរ មានរោម កោងចុះក្រោម ប្រវែង៤-៥សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនជារុក្ខជាតិចង្រៃខ្លាំង ក្នុងដំណាំចំការទេ។

## ឯកសារយោង: ២

# បន្លាស្អិត - *Mimosa invisa* (Banlar Saeth)



## របាយ

មានដុះនៅក្នុងលក្ខខ័ណ្ឌសើម។ ដុះរាយប៉ាយលើដីទំនេរ ចំការដំណាំពហុវត្ស ដងផ្លូវ និងព្រៃចំការ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្សពហុវត្ស។ ដើម: ឈរត្រង់ តោងឡើងកំពស់១,០-២,០ ម៉ែត្រ សំគាល់ដោយមានបន្លាកោងមុត មានរោម។ ស្លឹក: ស្និតរួម មានចំនួន១៥-៣០គូ ទទួលរំញោចនៅពេលប៉ះ។
កញ្ចុំផ្កា: ពណ៌ផ្កាឈូក។ ផ្លែ: កួរ មានបន្លា។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះតាមព្រៃចំការ និងរបងរស់ តែមិនដុះជាទូទៅក្នុងចំការដំណាំ។

## ឯកសារយោង: ២ និង ៧

# ព្រះខ្លបយក្ស - *Mimosa pigra* (Phreah Khlob Yeak)



## របាយ

មានដុះនៅក្នុងលក្ខខ័ណ្ឌសើម វាលភក់ រាយប៉ាយច្រើនតាមបណ្តោយទន្លេមេគង្គ និងទន្លេសាប។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្សពហុវស្ស។ ដើម: មានជាតិឈើ លូតលាស់លឿន រឹងមាំ មានបន្លា និងកំពស់២-៤ម៉ែត្រ។ ស្លឹក: ស្និតរួម ប្រវែងជាង២០សង់ទីម៉ែត្រ។ ផ្កា: ពណ៌ផ្កាឈូក។ ផ្លែ: កួរ មានរោមកោងបន្តិច ប្រវែង៥-១០សង់ទីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

នេះជារុក្ខជាតិចង្រៃចំបងមួយក្នុងតំបន់ទំនាប និងជាឧបសគ្គដ៏ធំមួយដល់ការអភិវឌ្ឍន៍កសិកម្ម នៅក្នុងតំបន់ទាំងនេះ។

## ឯកសារយោង: ២

# ព្រះខ្លប - *Mimosa pudica* (Phreah Khlob)



## របាយ

ដុះរាយប៉ាយច្រើនតាមដងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស ឬជួនកាលឯកវត្ស។ ដើមៈ មានជាតិឈើ បែកមែកច្រើន ឈរត្រង់ ទៅវារគ្របដីកំពស់២០-១០០ សង់ទីម៉ែត្រ រឹង និងមានបន្លាពោរពេញ។ ស្លឹកៈ ស្មិតរួមដែលមាន កូនស្លឹករួម១-២។ បន្តពូជដោយគ្រាប់ដែលអាចនាំដោយសត្វ សំលៀកបំពាក់ជាដើម។ អាចធន់នឹងម្លប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិចង្រៃជាទូទៅសំរាប់ដំណាំចំការ រួមទាំងដំណាំបន្លែមួយចំនួន ចំការដំណាំពហុវត្ស និងវាលស្មៅ។ ដើមមានបន្លាច្រើន ធ្វើឱ្យសត្វ ពិបាកស៊ី និងពិបាកកំចាត់ចេញពីដំណាំដោយប្រើដៃ។

## ឯកសារយោងៈ ២ និង ៧

# វល្លិ៍កន្ទុយកណ្ដុរ - *Macroptilium atropurpureum* (Voir Kuntuy Kandorl)



## របាយ

ដុះតាមដងផ្លូវ ដីទំនេរ វាលស្មៅ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវស្ស។ ដើម: វារគ្របរុំព័ទ្ធ ប្រវែង១០_៣០សង់ទីម៉ែត្រ។
ស្លឹក: រូមបី។ កញ្ចុំផ្កា: ចង្កោម ដែលមានផ្កាលើទងខ្លី៦_១២។
ផ្កា: ពណ៌ស្វាយចាស់ ដែលមានលាយក្រហម នៅជិតគល់ផ្កា។
ផ្លែ: កួរ ត្រង់ រាងដូចចំពុះសត្វ មានរោមប្រវែង៥_១០សង់ទីម៉ែត្រ និងអង្កត់ផ្ចិត៣_៥មីលីម៉ែត្រ និងប្រេះបែកពេលទុំ។

## សារៈសំខាន់ក្នុងកសិកម្ម

ប្រភេទសណ្ដែក ដាំសំរាប់ព្រលែងសត្វអោយស៊ី និងអាចច្រូតកាត់ធ្វើជាចំណីសត្វផងដែរ ទោះជាដើមវល្លិ៍វាររុំព័ទ្ធអាចពិបាកក្នុងការច្រូតកាត់ក៏ដោយ។ អាចប្រើធ្វើជាចំណីសត្វ ដោយព្រួសលាយជាមួយស្រូវចំការ។ អាចដាំជាដំណាំគម្របដីផងដែរ ដែលជួយបង្កើនជាតិអាសូតក្នុងដី មុនពេលដាំពោត។ ដោយសារគ្រាប់រឹង រុក្ខជាតិនេះអាចដុះក្នុងដំណាំដែលដាំបន្ទាប់។

## ឯកសារយោង: ៤

# ដើមម្រេចទន្សាយ - *Hyptis suaviolens* (Deum Moreck Tunsay)



## របាយ

ដុះតាមចំការដំណាំពហុវត្ស ដងផ្លូវ ដីទំនេរ និងវាលស្មៅ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: មានរោម ឈរត្រង់ បែកមែក និងកំពស់៥០-១៥០សង់ទីម៉ែត្រ។ ស្លឹក: រាងស៊ុតស្រួចចុងប្រវែង ៤-៩សង់ទីម៉ែត្រ។ ផ្កា: ពណ៌ខៀវស្វាយ មានផ្កា៣ រឺ៤ ក្នុងចង្កោមផ្កានៅគល់ស្លឹក។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះ ត្រូវបានសង្កេតឃើញមានដុះនៅតាមដងផ្លូវ តែមិនមែនជារុក្ខជាតិចង្រៃនៃដំណាំចំការទេ។

## ឯកសារយោង: ១

# ម្ជូរព្រឹកព្រៃ - *Abelmoschus moschatus* (Mchhu Preokprey)



## របាយ

មានដុះនៅតាមដីទំនេរ ទីប្លូរទំរង់ និងវាលភក់។ មានដុះតាមធម្មជាតិក្នុងចំការដំណាំពហុវត្ស វាលស្រែ កន្លែងកាប់ឆ្ការរួច និងឃើញមានតាមដងផ្លូវលំ និងជាយព្រៃផងដែរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេស វីមានលក្ខណៈជាចុល្លិ៍ព្រឹក្ស។ ដើមៈ កំពស់១,៥ ម៉ែត្រ។ ស្លឹកៈ មានទំរង់ និងទំហំផ្សេងៗគ្នា។ ផ្កាៈ ទោលនៅលើមុំគល់ស្លឹក ភាគច្រើនពណ៌លឿង និងស្វាយចាស់នៅផ្នែកខាងគល់ផ្កា។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនមែនជារុក្ខជាតិចង្រៃខ្លាំង ក្នុងដំណាំចំការឯកវត្សទេ។

## ឯកសារយោងៈ ១

# ត្បាល់កិន - *Abutilon indicum* (Tbal Ken)



## របាយ

ឃើញមានដុះនៅតាមដីទំនេរ ដងផ្លូវ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើម: មានរោម បែកមែក។ ស្លឹក: រាងបេះដូង គែមដូចធ្មេញ។ ផ្កា: ពណ៌លឿង ដែលមានទងភ្ជាប់ខាងលើ ផ្នែកកណ្តាល។ ផ្លែ: គ្មានសាច់ មានរោមក្រាស់ ដែលមានឡូតខ័ណ្ឌដាច់ពីគ្នា។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មិនមែនជារុក្ខជាតិចង្រៃខ្លាំង ក្នុងដំណាំចំការទេ។

## ឯកសារយោង: ២

# ក្រជិប - *Pentapetes phoenicea* (Krachib)

## របាយ

ឃើញមានដុះនៅតាមតំបន់ស្រូវឡើងទឹក ជងថ្នល់ និងចង្អូរទឹក។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

វារីតិណទេសឯកវស្ស (តិណទេសដុះក្នុងទឹកឯកវស្ស)។ ដើម: ឈរត្រង់ ពណ៌បៃតង កំពស់ដល់២,០ម៉ែត្រ។ ស្លឹក: រាងផ្លែលំពែងត្រង់ គែមដូចធ្មេញ។ ផ្កា: ទោល នៅលើមុំគល់ស្លឹក។ បន្តពូជដោយគ្រាប់។



## សារៈសំខាន់ក្នុងកសិកម្ម

មិនទំនងជារុក្ខជាតិចង្រៃក្នុងដំណាំចំការទេ។

## ឯកសារយោង: ២

# កន្ទ្រាំងបាយស - *Sida acuta* (Kantraing Bay Sar)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌដីខ្សាច់ស្ងួត រាយប៉ាយក្នុងចំការដំណាំ ដងផ្លូវ ដីទំនេរ និងវាលស្មៅ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្ស រីតិណទេសឯកវស្ស។ ដើម: តូច ឈរត្រង់ បែកមែកច្រើន កំពស់៣០-១០០សង់ទីម៉ែត្រ មានឫសកែវ រឹងមាំ។ ផ្លែ: គ្មានសាច់ ខ័ណ្ឌជាច្រើនឡូត ដែលឡូតនីមួយៗមានគ្រាប់១។ គ្រាប់មានកន្ទុយ អាចតោងស្អិតជាប់ដងខ្លួនសត្វ និងសំលៀកបំពាក់របស់មនុស្ស ដែលជួយធ្វើឱ្យរីកសាយភាយពូជ។ បន្តពូជធ្វើឡើងដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះប្រជែងខ្លាំង។ លូតលាស់ល្អលើដីច្រើនប្រភេទ រួមទាំងដីឥដ្ឋ។ អាចធន់នឹងកន្លែងសើម និងតំបន់ស្ងួត។ បើមិនភ្ជួររាស់ ឬប្រើថ្នាំសំលាប់ គឺពិបាកក្នុងការគ្រប់គ្រងណាស់ ដោយសារដើមមានសរសៃស្វិត និងឫសកែវរឹងមាំ។ ភ្ជួររាស់បន្តបន្ទាប់គ្នា អាចសំលាប់បាន តែឫសកែវចាក់ជ្រៅធ្វើឱ្យពិបាកក្នុងការរៀបចំដី។ សត្វមិនចូលចិត្តស៊ីទេ។

**ឯកសារយោង: ២ និង ៧**

# កន្ទ្រាំងបាយសញី - *Sida rhombifolia* (Kantraing Bay Sar Nhi)

## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌដីខ្សាច់ស្ងួត។ ដុះរាយប៉ាយក្នុងចំការដំណាំ ដងផ្លូវ ដីទំនេរ និងវាលស្មៅ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើមៈ តូច ឈរត្រង់ បែកមែកកំពស់៣០-១០០ សង់ទីម៉ែត្រ។ ស្លឹកៈ ពណ៌បៃតងភ្លឺ វែងតូចជាងស្លឹកកន្ទ្រាំងបាយស។ ផ្លែៈ គ្មានសាច់ ខ័ណ្ឌជាច្រើនឡូត ដែលឡូតនីមួយៗមានគ្រាប់១។ កន្ទុយគ្រាប់អាចស្អិតជាប់សត្វ សំលៀងបំពាក់ ដែលជួយក្នុងការសាយពូជ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះប្រជែងខ្លាំង។ លូតលាស់ល្អលើដីច្រើនប្រភេទ រួមទាំងដីអិដ្ឋ។ អាចធន់នឹងកន្លែងសើម និងតំបន់ស្ងួត។ បើមិនភ្ជួររាស់ ឬប្រើថ្នាំសំលាប់ គឺពិបាកក្នុងការគ្រប់គ្រងណាស់ ដោយសារដើមមានសរសៃស្វិត និងឫសកែវរឹងមាំ។ ភ្ជួររាស់បន្តបន្ទាប់គ្នាអាចសំលាប់បាន តែឫសកែវចាក់ជ្រៅធ្វើឱ្យពិបាកក្នុងការរៀបចំដី។ សត្វមិនចូលចិត្តស៊ីទេ។

**ឯកសារយោងៈ ២ និង ៧**



# ស្មៅអាចម៍ជ្រូក _ *Urena lobata* (Smao Ach Chruk)

## របាយ

ដុះរាលដាលតាមទីប្លូរទំរង់ ដីទំនេរ ដងផ្លូវ និងវាលស្មៅ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ចុល្លព្រឹក្ស។ ដើម: ឈរត្រង់ កំពស់១ម៉ែត្រ។ ស្លឹក: ឆែក (មានជ្រុង)៥ រាងដូចបាតដៃប្រវែង៤_៨សង់ទីម៉ែត្រ។
ផ្កា: ពណ៌ផ្កាឈូកស្វាយ ទំហំ១សង់ទីម៉ែត្រ។
ផ្លែ: មានរោម កោងដូចទំពក់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិចង្រៃសំខាន់ក្នុងចំការអំពៅ វាលស្មៅ ដីកាប់ឆ្ការរួច និងវាលស្មៅ។

## ឯកសារយោង: ១



# ផ្ទីថ្មឈ្មោល _ *Boerhavia diffusa* (Phti Thmar Chhmol)



## របាយ

ឃើញមានដុះជាទូទៅនៅតាមដីទំនេរ ដងផ្លូវ វាលស្មៅ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវស្ស ឬពហុវស្ស។ ដើម: បែកមែកទូលាយសន្ធឹងគ្របដី ដុះគ្របដីពីដំបូង បន្ទាប់មកក៏ដុះឈរត្រង់ កំពស់៤០_១៥០ សង់ទីម៉ែត្រ មានពណ៌ក្រហម ទៅស្វាយ និងមានរោមតិចតួច។ ស្លឹក: ពណ៌បៃតងចាស់ ទៅស្វាយ ប្រវែង១_៥ សង់ម៉ែត្រ គែមរាងទឹករលក ឬជ្រុង។ ផ្កា: ពណ៌ស ទៅផ្កាឈូក ប្រវែង១,៥_២,៥មីលីម៉ែត្រ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិចង្រៃជាទូទៅ ដុះក្នុងចំការដំណាំឯកវស្ស ចំការដំណាំពហុវស្ស វាលស្មៅ និងដីទំនេរ។ មានឫសកែវធំក្រាស់ និងអាចធន់បាននៅរដូវប្រាំង។ បើមិនដកសំអាតចេញពីចំការពោត វីសណ្តែកសៀងទេ ទិន្នផលដំណាំអាចថយចុះ៧០_៨០%។

## ឯកសារយោង: ២ និង ៣

# សាវម៉ៅព្រៃ - *Passiflora foetida* (Sav Mao Prey)



## របាយ

ឃើញមានដុះនៅតាមចំការដាំដំណាំ ដងផ្លូវ ដីទំនេរ និងរបង។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើម: មានរោម វារឡើង វារសន្ទឹងប្រវែងដល់៦,០ម៉ែត្រ។ ស្លឹក: ឆ្លាស់ គែមមានជ្រុង៣។ ផ្កា: ទោលពណ៌សដែលមានពណ៌ស្វាយនៅគល់ផ្កា ឃើញមានដុះនៅលើម៉ុំគល់ស្លឹក។ ផ្លែ: ហ៊ុំព័ទ្ធដោយបញ្ចុំត្របកផ្កាពណ៌បៃតង ដូចសំណាញ់។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះដុះជាទូទៅតាមតំបន់ខ្ពស់ បណ្តោយដងផ្លូវ តែដោយសារធម្មជាតិរបស់វាជារុក្ខជាតិពហុវត្ស វាមិនទំនងជាចង្រៃខ្លាំង ក្នុងប្រព័ន្ធដាំដុះដំណាំឯកវត្សទេ។

## ឯកសារយោង: ២ និង ៣

# ស្មៅបារាំង - *Brachiaria mutica* (Smao Barang)

## របាយ

មានដុះនៅក្នុងលក្ខខ័ណ្ឌដីដក់ទឹក។ ឃើញមានដុះតាមវាលស្រែ ចង្អូរទឹក និងមិនធន់នឹងលក្ខខ័ណ្ឌស្ងួត ដែលមានរយៈពេលយូរទេ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅពហុវត្ស។ ដើមៈ វារលើដី ខ្នែងគ្រើមធំ វែង ប្រវែងដល់ ៥,០ម៉ែត្រ មានរោមច្រើន។ ស្លឹកៈ មានរោមមធ្យម ទន់ ទទឹង ២០មីលីម៉ែត្រ និងបណ្ដោយ៣០សង់ទីម៉ែត្រ។ ខ្នែង និងមែក មានឫសជាស្រេចនៅតាមថ្នាំ។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះប្រែប្រួលលើដីច្រើនប្រភេទ សមស្របលើដីដោះ ឬស្រស់ទឹក និងដុះលូតលាស់លើដីដោះ ឬស្រស់ទឹក ផងដែរ។ អាចជាបញ្ហានៅតំបន់ដីសើម ដែលមិនមែនជាវាលស្មៅ ដូចជាចំការអំពៅ ចង្អូរទឹកស្រោចស្រព និងចង្អូរដក់ទឹក។ ច្រូតកាត់ធ្វើជាចំណីសត្វនៅប្រទេសកម្ពុជា។

**ឯកសារយោងៈ ២ ៣ និង ៧**



# ស្មៅគោ - *Brachiaria reptans* (Smao Ko)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌស្ងួត។ ឃើញមានដុះតាមដីទំនេរ ចំការដំណាំ និងរាយប៉ាយពាសពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

ស្មៅពហុវត្ស។ ដុះរាលដាល ដោយខ្នែងដែលមានឫសតាមថ្នាំ។ ស្លឹក: មានប្រវែង២-៥សង់ទីម៉ែត្រ និងទទឹង១,០-១,៥សង់ទីម៉ែត្រ មានរោមតិចជាងស្មៅបារាំង។ កញ្ចុំគ្រាប់: មានប្រវែង២-៦ សង់ទីម៉ែត្រ បែកជា៥-១៥មែក។ មានផ្កាពេញមួយឆ្នាំ។ សាយពូជដោយខ្នែង (ដើម) និងគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

អាចរស់ពេញរដូវប្រាំង បន្តពូជដោយគ្រាប់ អាចដុះប្រជែងខ្លាំងក្នុងដំណាំចំការ។ ច្រូតកាត់ធ្វើជាចំណីសត្វនៅប្រទេសកម្ពុជា។

## ឯកសារយោង: ២

# ស្មៅចិញ្ចៀន - *Cynodon dactylon* (Smao Chenh Chean)



## របាយ

ស្មៅពហុវត្សដុះជាទូទៅតាមដងផ្លូវ វាលស្មៅ ដីទំនេរ និងដំណាំចំការនៅប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅពហុវត្ស។ ដុះគ្របដី មានស្លឹកល្អិត។ វាដុះឫសតាមថ្នាំ និងមានខ្នែងក្រោមដីផងដែរ ដែលអាចធ្វើអោយវារាលដាលយ៉ាងឆាប់រហ័សក្នុងវគ្គលូតលាស់។ សាយពូជភាគច្រើនដោយខ្នែង ក្នុងវគ្គលូតលាស់ និងមានដាក់គ្រាប់តិចតួច ដូច្នេះការគ្រប់គ្រងត្រូវផ្តោតលើការការពារការរាលដាល ដោយសត្វពាហនៈ និងគ្រឿងយន្តកសិកម្ម។ល។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិចង្រៃក្នុងដំណាំចំការជាច្រើនប្រភេទ។ តែវាមានប្រយោជន៍ផងដែរសំរាប់វាលស្មៅចំណីសត្វ និងការការពារការហូរច្រោះ។ ដុះលើដីមានកំរិត pH ច្រើនប្រភេទ និងល័ក្ខខ័ណ្ឌ សំណើម តែល្អលើប្រភេទដីឥដ្ឋមធ្យម ទៅដីឥដ្ឋខ្លាំង។

## ឯកសារយោងៈ ៧

# ស្មៅជើងក្រាស់ - *Dactyloctenium aegyptium* (Smao Cheung Kra)

## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌស្ងួត អាចរស់ក្នុងរដូវប្រាំង ក្នុងប្រទេសកម្ពុជា។ ឃើញមានដុះនៅក្នុងដំណាំចំការ ដីទំនេរ និងរាយប៉ាយពាសពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅតិណទេសឯកវត្ស កំពស់៥០-១៥០សង់ទីម៉ែត្រ ដើមទន់ស្លឹកមានជាតិទឹកតិចតួច។ មានផ្ទុកសមាសធាតុខ្យានីត (cyanide) ដែលជាសារធាតុពុលម្យ៉ាង អាចមានគ្រោះថ្នាក់ ក្នុងការរក្សាទុកក្នុងកំឡុងពេលជាក់លាក់ណាមួយ។ វាជាស្មៅមួយប្រភេទដ៏ប្រសើរសម្រាប់អោយសត្វស៊ី ក្នុងតំបន់ស្ងួតសើម តែស្វិតក្រៀមនៅដើមរដូវប្រាំង។ ដើមៈ មូល ឈរត្រង់ ឬគ្របដី តាន់ និងគ្មានរោម។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះជាប្រភេទស្មៅចង្រៃក្នុងដំណាំចំការ ដូចជាពោត កប្បាស អំពៅ និងសណ្តែកដី។ ថ្នាំសំលាប់ស្មៅជាច្រើនប្រភេទ អាចកំចាត់ស្មៅនេះបាន។

## ឯកសារយោងៈ ២ និង ៧



# ស្មៅសំបុកមាន់ - *Digitaria adscendens* (Smao Sambok Mon)



## របាយ

មានដុះនៅក្នុងល័ក្ខខ័ណ្ឌខ្ពស់។ ឃើញមានដុះតាមដីទំនេរ ចំការ និងមានពាសពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅឯកវត្ស។ ដើម: កំពស់៣០-៥០សង់ទីម៉ែត្រ។ ស្លឹក: រាងផ្លែលំពែងត្រង់ មានរោមនៅលើស្រទបស្លឹក និងផ្នែកចំហនៃតួស្លឹក។ កញ្ចុំគ្រាប់: កួរវែងតូច បែកខ្នែង៥-៨ ដែលខ្នែងនីមួយៗប្រវែង១០សង់ទីម៉ែត្រ។ សត្វចូលចិត្តស៊ី ពេលនៅខ្ចី។ មានផ្កាពេញមួយឆ្នាំ។ ជាញឹកញាប់ដុះលូតលាស់លឿន នៅពេលដែលរុក្ខជាតិដទៃទៀតរងសម្ពាធនៃសីតុណ្ហភាព និងទឹក។ ពន្លកស្មៅមានឫសនៅតាមថ្នាំង។

## សារៈសំខាន់ក្នុងកសិកម្ម

ពិបាកគ្រប់គ្រង ដោយការភ្ជួរពេលដុះដំបូង។ ប្រជែងយ៉ាងខ្លាំងក្នុងការស្រូបយកសំណើម និងសារធាតុចិញ្ចឹម។ ស្មៅនេះត្រូវបានយកទៅធ្វើជាសំបុកមាន់។

## ឯកសារយោង: ២ និង ៣

# ស្មៅបែកក្បាលគ្មានកន្ទុយ - *Echinochloa colona* (Smao Bek kbal Khmeankantuy)



## របាយ

មានដុះនៅលើដីមានសំណើម និងស្ងួត។ ឃើញមានដុះនៅលាយឡំក្នុងស្រូវពង្រោះ និងចំការដំណាំ។ ដុះរាយប៉ាយពេញប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅឯកវត្ស។ ដើម: កញ្ចុំរួមគ្នា ឈរត្រង់ ជាញឹកញាប់គ្របដីកំពស់៣០-៦០សង់ទីម៉ែត្រ ពណ៌ក្រហមស្វាយ រឺបៃតង។ ស្លឹក: ត្រង់ប្រវែង១០-១៥សង់ទីម៉ែត្រ។ កញ្ចុំផ្លែ: កួរ ខ្នែង(បែកមែក) ៣-១៩ ដែលមានប្រវែង៥-១៥សង់ទីម៉ែត្រ។ សាយពូជដោយគ្រាប់។ ដើមមួយអាចផលិតគ្រាប់បានដល់៤០,០០០គ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

លូតលាស់ក្នុងល័ក្ខខ័ណ្ឌសើម។ ប្រភពមួយនៃការដុះរាលដាល អាចមកពីការដាំគ្រាប់ដំណាំដែលមានលាយគ្រាប់ស្មៅនេះ។ ការរៀបចំដី ពេលវេលា និងវិធីសាស្ត្រដាំ ការលូតលាស់ ចន្លោះគុម្ព-ជួរ និងការប្រើជី។ ការគ្រប់គ្រងអាចប្រើវិធានការចំរុះគ្រប់គ្រងស្មៅចង្រៃ។

## ឯកសារយោង: ២

# ស្មៅទន្សោង - *Eleusine indica* (Smao Tunsorng)

## របាយ

មានដុះនៅលើដីមានសំណើមទាប។ ឃើញមាននៅតាមដីទំនេរ ដងផ្លូវ និងចំការដំណាំ។ ធន់នឹងការដើរជាន់ ឬសង្កត់។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅឯកវត្ស។ ដើម: ដុះជាកញ្ចុំ ឈរត្រង់ ឬគ្របដីផ្នែកខាងក្រោម កំពស់ដល់៨០សង់ទីម៉ែត្រ។ ស្លឹក: តួស្លឹកប្រវែង១០-៣០សង់ទីម៉ែត្រ ស្រទបស្លឹកប្រវែង៦-៩សង់ទីម៉ែត្រ សំប៉ែតខាងៗ ដែលមានរោមវែងមួយៗ ត្រង់ចំនុចប្រសព្វជាមួយតួស្លឹក។ លូតលាស់ល្អក្នុងតំបន់ក្តៅ និងល័ក្ខខ័ណ្ឌស្ងួត។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

លូតលាស់ក្នុងដំណាំច្រើនប្រភេទ។ ឃើញមានដុះនៅតាមដីទំនេរ ដោយធន់នឹងភាពរាំងស្ងួត។ ជាធម្មតាគ្រប់គ្រងដោយការភ្ជួររាស់ និងការរៀបចំដី។ ម្យ៉ាងទៀត អាចគ្រប់គ្រងបានល្អដោយការប្រើថ្នាំជាច្រើនប្រភេទ រួមទាំងថ្នាំដែលមានតំលៃថោកផងដែរ។

## ឯកសារយោង: ២ និង ៧



# ស្បូវភ្លាំង - *Imperata cylindrica* (Sbov Phlang)



## របាយ

លូតលាស់លើដី ទាំងសើម និងស្ងួត។ ដុះរាយប៉ាយតាមដីទំនេរ ទីលំហក្នុងព្រៃ និងជួនកាលក្នុងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ស្មៅពហុវស្ស។ ដើមៈ ឈរត្រង់ រឹងមាំ មានរោមនៅតាមថ្នាំងកំពស់ ០,៥-១ម៉ែត្រ។ បន្តពូជដោយគ្រាប់ និងឫស (ដើមក្រោមដី)។ ជាទូទៅចេញផ្កា នៅពេលមានសម្ពាធពីកត្តាខាងក្រៅ ដូចជាការដុត ការកាត់ដើម ឬភាពរាំងស្ងួត។ គ្រាប់ជាច្រើនត្រូវបានបង្កើត និងអាចរាលដាលទៅឆ្ងាយដោយខ្យល់។ ធន់នឹងការដុត និងដុះឡើងវិញយ៉ាងរហ័សចេញពីឫស (ដើមក្រោមដី) ដែលការពារពីការដុតដោយកប់ក្នុងដី។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិចង្រៃជាទូទៅក្នុងចំការកៅស៊ូ ឈើហូបផ្លែ និងចំការដំណាំ ជាពិសេសនៅរដូវប្រាំង តែមិនទំនងជាធន់នឹងការភ្ជួររាស់ទេ។

## ឯកសារយោងៈ ២ និង ៧

# ត្រែង - *Sorghum halepense* (Treng)



## របាយ

មានដុះនៅតាមដងផ្លូវ ជួនកាលក្នុងដំណាំ នៅខេត្តបាត់ដំបង។ ទំនងជាដុះរាលដាលតាមដងផ្លូវ នៅភាគពាយព្យនៃប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ពហុវត្សរ។ ដើម: ឈរត្រង់ កំពស់១,៥ម៉ែត្រ ដែលមានឫស (ដើមក្រោមដី) រឹងមាំ ថ្នាំងមានរោមខ្លីៗ។ ស្លឹក: ទទឹង ១-១,៥សង់ទីម៉ែត្រ ទ្រនុងស្លឹកផុសចេញ។ កញ្ចុំគ្រាប់: ប្រវែង១៥-២៥សង់ទីម៉ែត និងកន្សោមផ្កាប្រវែង៥ មីលីម៉ែត្រ។ រុក្ខជាតិមានដុះឫស (ដើមក្រោមដី) វែង មានពន្លកជាច្រើន ដែលដុះចេញបណ្ដូលយ៉ាងរហ័ស។ ការដាក់គ្រាប់គឺប្រែប្រួល និងអាស្រ័យលើកត្តាបរិស្ថាន។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិប្រភេទនេះអាចជារុក្ខជាតិចង្រៃខ្លាំងក្នុងការដាំដុះ បើវាមានដុះក្នុងចំការដំណាំ មុនពេលធ្វើការដាំដុះដំណាំ។

## ឯកសារយោង: ១ និង ៧

# ក្បិតជូន_ *Portulaca oleracea* (Kambet Chun)



## របាយ

មានដុះនៅក្នុងចំការដំណាំ បន្លែ និងដីទំនេរ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ឯកវត្សរ។ ដើមៈ គ្របដី ក្រាស់ទន់ មានជាតិទឹក ដែលធន់នឹងដីរីងខ្សត់ជី និងភាពរាំងស្ងួត។ ជាទូទៅដើម ពណ៌ក្រហមស្វាយ មានដុះឫសចេញពីថ្នាំងនៅខាងក្រោម។ ដើមបែកមែកច្រើន ដែលមានប្រវែងដល់៦០សង់ទីម៉ែត្រ និងលូតលាស់គ្របសន្ធឹង បង្កើតជាកម្រាលលើដី។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

ពេលដុះដំបូង វាធន់នឹងភាពរាំងស្ងួត។ ការគ្រប់គ្រងដោយមិនប្រើថ្នាំសំលាប់ និងដោយប្រើបច្ចេកទេសដាំដុះសមស្រប រុក្ខជាតិនេះនឹងដុះក្រាស់ល្អគ្របលើដី។ បើកំចាត់ដោយប្រើគ្រឿងយន្តត្រូវបំផ្លាញដើមចោល បើពុំនោះទេកំណាត់ដើមនឹងដុះក្នុងលំហដី។ វិធីគ្រប់គ្រងទទួលបានផលល្អ គឺការប្រើថ្នាំសំលាប់ជាច្រើនដងក្រោយពេលដុះ។

## ឯកសារយោងៈ ២

# ម្អមភ្នំញី - *Borreria alata* (Maam Phnom Nhi)



## របាយ

ពីមុនរុក្ខជាតិនេះ ជាបញ្ហាមួយក្នុងចំការដំណាំពហុវត្ស តែឥឡូវ ជារុក្ខជាតិចង្រៃមួយ ក្នុងដំណាំចំការនៅតំបន់ត្រូពិក និងតំបន់ទ្រនាប់ត្រូពិក។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: គ្របដី តោងឡើង ឬឈរត្រង់ ប្រវែង ៥០-១០០សង់ទីម៉ែត្រ ទំនងជាមានជាតិទឹក និងរាងបួនជ្រុង។

ស្លឹក: ប្រវែង២-៧សង់ទីម៉ែត្រ និងមានទំរង់ផ្សេងគ្នា។

ផ្កា: ចង្កោមក្រាស់ នៅជាប់នឹងគល់ស្លឹក។

## សារៈសំខាន់ក្នុងកសិកម្ម

ដោយសារ*ម្អមភ្នំញី* នៅតែរាលដាល វាត្រូវបានចាត់ទុកថាជាប្រភេទរុក្ខជាតិចង្រៃថ្មីមួយ នៅតាមតំបន់មួយចំនួន។ វាជារុក្ខជាតិចង្រៃខ្លាំងក្នុងចំការដំណាំពហុវត្ស ដំឡូងមី ពោត សណ្តែកសៀង និងបន្លែ។

## ឯកសារយោង: ១

# កំប៉ោយចិន _ *Hedyotis diffusa* (Kampoy Chen)



## របាយ

មានដុះនៅតាមដីលំហ ដងផ្លូវ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើម: តូច សន្ធឹងគ្របដី ឬតោងឡើង បែកមែកតិច ឬច្រើន ប្រវែងដល់៥០សង់ទីម៉ែត្រ។ ស្លឹក: ត្រង់ ប្រវែង១_៣សង់ទីម៉ែត្រ។ ផ្កា: ពណ៌ស ប្រវែង៣មីលីម៉ែត្រ ទោល នៅលើម៉ុគល់ស្លឹក។ ផ្លែ: គ្មានសាច់ ប្រវែង៤មីលីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

មិនមែនជារុក្ខជាតិចង្រៃក្នុងចំការដំណាំទេ។

## ឯកសារយោង: ២

# ម្អមភ្នំឈ្មោល - *Richardia brasiliensis* (Maam Phnom Chhmol)



## របាយ

ដុះពាសពេញក្នុងដំណាំចំការ និងវាលស្មៅ នៅភាគពាយព្យប្រទេសកម្ពុជា។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើមៈ សន្ទឹងគ្របដី បែកមែក និងមានរោម។ ស្លឹកៈ ឈម រាងស៊ុតស្រួចចុង ក្រាស់។ ផ្កាៈ នៅចុងដើមពណ៌សទំរង់ដូចជីឡាវ។ បន្តពូជដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅក្នុងល័ក្ខខ័ណ្ឌដីស្ងួត។

## ឯកសារយោងៈ ២

# អំបែងបែក - *Cardiospermum halicacabum* (Ambeng Bek)



## របាយ

មានដុះនៅតាមដងផ្លូវ ចំការ ជាពិសេសនៅខេត្តបាត់ដំបង។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសពហុវត្ស។ ដើម: ដុះតោងឡើង កំពស់ដល់៨ម៉ែត្រ។ ស្លឹក: ឆ្លាស់ រាងស្នៀរ ស្មិតរូម។ កូនស្លឹក: ប្រវែង២៨-៦២មីលីម៉ែត្រ និងទទឹង១០-៤៣មីលីម៉ែត្រ គែមរាងធ្មេញរណា ដូចធ្មេញ ឬឆែកចូលជ្រៅក្នុងតួស្លឹក។ ផ្កា: ពណ៌ស ប្រវែង១,៥-៥ មីលីម៉ែត្រ ជាចង្កោម។ ផ្លែ: គ្មានសាច់ ប៉ោង ប្រវែង១២-៤១មីលីម៉ែត្រ និងទទឹង១៥-៤៤មីលីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

ដុះផ្តុំគ្នាក្រាស់ តែមិនរាលដាល។ អាចគ្រប់គ្រងដោយប្រើ ថ្នាំសំលាប់ និងគ្រឿងយន្តកសិកម្ម។

## ឯកសារយោង: ៥

# ប៉េងប៉ោះស្រោម _ *Physalis angulata* (Peng Pos Srom)



## របាយ

មានដុះនៅលើដីដោះ ឬស្រស់ទឹកល្អ តាមដងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស។ ដើមៈ មានរោម ឈរត្រង់ បែកមែក និងកំពស់៣០_៤០សង់ទីម៉ែត្រ។ ស្លឹកៈ ឆ្លាស់ គែមមិនស្មើលយ ចេញតិចតួច។ ផ្កាៈ រាងដូចជួង ពណ៌លឿងស្លេក និងស្វាយ នៅផ្នែកខាងគល់។ ផ្លែៈ ហួបបាន មូលតូចស្រោបដោយ ត្របកផ្កាស្តើងដូចក្រដាស។ រាលដាលដោយគ្រាប់។

## សារៈសំខាន់ក្នុងកសិកម្ម

មានដុះនៅក្នុងចំការ វាលស្មៅ ដងផ្លូវ ទីលំហនៃព្រៃ ទីប្តូរទំរង់។ វាងាយរងនឹងថ្នាំសំលាប់ច្រើនប្រភេទ ហើយគ្រាប់ដែលកប់ជ្រៅ ក្នុងដីមិនអាចដុះបានទេ។ ក្រៅពីធ្វើអោយទិន្នផលដំណាំថយចុះ គ្រាប់ទុំ អាចនៅលាយឡំជាមួយគ្រាប់ដំណាំ។

## ឯកសារយោងៈ ២ និង ៣

# ក្រចៅព្រៃ - *Corchorus olitorius* (Kro Chauv Prey)

## របាយ

ជាទូទៅ ឃើញមានដុះនៅក្នុងចំការដំណាំ ដីទំនេរ និងដងផ្លូវ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្រ្ត

តិណទេសឯកវស្ស។ ដើម: លូតលាស់ប្រវែង៣០-១០០សង់ទីម៉ែត្រ។ ស្លឹក: គ្មានរោម ប្រវែង៥-១២សង់ទីម៉ែត្រ គែមរាងដូចធ្មេញរណា នៅផ្នែកខាងក្រោមមានរាងធ្មេញធំ ទាំងសងខាងដូចត្រចៀក។ ផ្កា: មានស្រទាប់៥ ពណ៌លឿង ប្រវែង៤-៥មីលីម៉ែត្រឈមនឹងស្លឹក។ ឫសកែវលូតលាស់ខ្លាំង ធ្វើអោយធន់នឹងភាពរាំងស្ងួតក្នុងដំណាក់កាលលូតលាស់ដំបូង។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះ មានប្រវត្តិជាយូរណាស់មកហើយ ក្នុងការប្រើធ្វើជាបន្លែនៅអាស៊ីអាគ្នេយ៍។ សន្តាននៃរុក្ខជាតិនេះ ត្រូវបានប្រើសំរាប់កែច្នៃជាផលិតផលសរសៃ។ ប្រភេទរុក្ខជាតិនេះជាច្រើនដុះប្រជែងខ្លាំងជាមួយដំណាំ។

## ឯកសារយោង: ២ និង ៣



# ស្មៅគ្រាប់ស្អិត - *Stachytarpheta indica* (Smao Krab Sa-eth)



## របាយ

មានដុះនៅតាមដងផ្លូវ ដីទំនេរ និងទីខ្ពស់។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

តិណទេសឯកវត្ស ឬពហុវត្ស។ ដើម: ទាប សន្ធឹងគ្របដី កំពស់ ០,៦-១,២ម៉ែត្រ ជួនកាលផ្នែកគល់មានជាតិឈើ ជាញឹកញាប់មានពណ៌ស្វាយ បែកមែក មានរោមរ៉ុយៗ។ ស្លឹក: ជាញឹកញាប់ពណ៌ខៀវរំប្រផេះ ពេលនៅស្រស់ ស្លឹកឆ្លាស់រឺឈម ក្រាស់ល្មម រាងទ្រវែង ទៅរាងពងក្រពើ ឬស៊ុតស្រួចចុង ប្រវែង២-៩សង់ទីម៉ែត្រ និងទទឹង១,៥-៤សង់ទីម៉ែត្រ។ កញ្ចុំផ្កា: រឹងមាំ ប្រវែង១៥-៥០សង់ទីម៉ែត្រ អង្កត់ផ្ចិត៧មីលីម៉ែត្រ។ ផ្កា: ពណ៌ខៀវស្លេក ប្រវែង ៨-១១មីលីម៉ែត្រ។

## សារៈសំខាន់ក្នុងកសិកម្ម

មិនត្រូវបានសង្កេតឃើញថា ជារុក្ខជាតិចង្រៃដល់ដំណាំចំការទេ។

## ឯកសារយោង: ១

# វល្លិ៍ត្រដឹត - *Cayratia trifolia* (Voir Trardeth)



## របាយ

មានដុះនៅតាមដងផ្លូវ ដីទំនេរ និងចំការដំណាំ។

## ការពិពណ៌នា និងលក្ខណៈជីវសាស្ត្រ

ដើម: វល្លិ៍ រលោង ជាទូទៅប្រវែង៣-៨ម៉ែត្រ និងទទឹង២-៥សង់ទីម៉ែត្រ។ ស្លឹក: រួមបី ដែលមានកូនស្លឹករាងស៊ុតស្រួចចុងទៅរាងត្រីកោណ និងគែមស្លឹករាងធ្មេញស្រួច។ ដៃវល្លិ៍: ដុះឈមនឹងស្លឹកនីមួយៗ តាមបណ្តោយដើម។ កញ្ចុំផ្កា: ប្រវែង៦-១០សង់ទីម៉ែត្រ រាងសំប៉ែតត្រឹមវិរាងធំត្រ។ ផ្កា: តូចៗ ពណ៌ស ទៅពណ៌ពងមាន់។ ផ្លែ: តូចមូល ពណ៌បៃតងប្រែជាខ្មៅ ពេលទុំ។

## សារៈសំខាន់ក្នុងកសិកម្ម

រុក្ខជាតិនេះដុះនៅជុំវិញ/ក្នុងចំការដំណាំ តែមិនទំនងជាធន់នឹងការភ្ជួររាស់ជាបន្តបន្ទាប់គ្នាទេ។

## ឯកសារយោង: ១៤

# សន្ទានុក្រម

អត្ថន័យនៃពាក្យដែលទាក់ទងនឹងរុក្ខជាតិ ទទួលបានពីសៀវភៅ វចនានុក្រមហ្សតធ័រ អុកស្វ៊ត (Shorter Oxford Dictionary)។

**កញ្ចុំត្របកផ្កា**
បណ្តុំនៃត្របកផ្កា ជាទូទៅមានពណ៌បៃតង ដែលរុំស្រោបផ្កានៅពីខាងក្រៅ ពេលផ្កានៅក្រពុំ។

**កញ្ចុំផ្កា**
ការដុះប្រមូលផ្តុំតំរៀបគ្នានៃផ្កា លើរុក្ខជាតិកញ្ចុំផ្កា។

**កន្ទុយ (គ្រាប់)**
ចំនុច ឬផ្នែកស្រួចដុះលើសំបកគ្រាប់របស់ស្មៅនៅខាងចុង។

**កន្សោមផ្កា**
ក្រុមតូចមួយនៃផ្កាតូចៗជាច្រើនរបស់ស្មៅ ដែលបង្កើតបានជាផ្នែកមួយនៃកួរផ្កា។

**កេសរឈ្មោល**
ផ្នែកឈ្មោលនៃផ្កា។

**កោង**
ដែលកោង ដូចជាការបត់ត្រឡប់ក្រោយ។

**ខ្នែង (ឬដៃ)**
ខ្នែងនៃរុក្ខជាតិ។ ដើមដែលដុះវារលើដី។

**គ្មានទង**
គ្មានទង ដោយដុះចេញផ្ទាល់ពីមែក ឬដើម។

**គ្របដី**
សន្ទឹងគ្របលើដី។

**ចុង**
ចុង កំពូល ឬចំនុចបញ្ចប់។

**ចូលចិត្ត (ស៊ី)**
ក្លិន ឬរសជាតិ ដែលគួរអោយចូលចិត្ត (ស៊ី)។

**ឆែក**
គែមស្លឹកដែលមានរាងឆែក ឬចង្អូរចូលក្នុងតួស្លឹក។

**ជ័រ**
សារធាតុរាវដូចទឹកដោះគោ ដែលមាននៅក្នុងរុក្ខជាតិច្រើនប្រភេទដូចជាក្នុងគ្រួសារ Euphorbiaceae ហើយហូរចេញនៅពេលដែលរុក្ខជាតិរងការប៉ះរលាត់។

**ជ្រុង**
ដែលមានជ្រុង ឬគែមស្រួច (មិនមូល)។

**ជ្រុង (គែមឆែក ឬផ្ទៃមិនរាបស្មើនៃស្លឹក ឬផ្លែ)**
ផ្នែកលយចេញ រាងមូល។

**ឈរត្រង់**
ដែលដុះត្រង់ទៅលើ។

**ដៃ (វល្លិ៍)**
ផ្នែកដូចសរសៃអំបោះឆ្មារនៃរុក្ខជាតិ មានទំរង់ជាស្ពៀររមួរដែលលាតសន្ធឹង និងតោងភ្ជាប់ទៅនឹង ឬសរុំជុំវិញរុក្ខជាតិដទៃដើម្បីធ្វើជាទំរ។

**តិណទេស**
រុក្ខជាតិដែលមានដើមគ្មានជាតិឈើ និងងាប់បន្ទាប់ពីផ្ការួច។

**ត្របកផ្កា**
ផ្នែក ឬស្លឹកនិមួយៗនៃកញ្ចុំត្របកផ្ការបស់ផ្កាមួយ។

**ថ្នាំង**
ពកនៅលើឫស ឬមែក ជាចំនុចនៅលើដើមដែលស្លឹកដុះចេញ។

# សន្ទានុក្រម

**ទងផ្កា**
ទងរបស់ផ្កា ឬផ្លែ។

**ទងស្លឹក**
ទងរបស់ស្លឹក។

**ទោល**
ការដុះចេញដែលមានតែមួយ ឬដោយឡែក មិនបង្កើតជា ចង្កោម ឬបណ្តុំទេ។

**ទ្រនាប់ផ្កា**
ស្លឹកតូចៗដែលប្រែប្រួល ឬលូតលាស់ដូចស្រកានៅពីក្រោម ត្របកផ្កា រឺនៅពីលើទងផ្កា។

**នៅលើមុំគល់ស្លឹក**
ដែលស្ថិតនៅលើ ឬដុះចេញពីមុំគល់ស្លឹក។

**ប្រេះបែក**
សំបកគ្រាប់ប្រេះបែកនៅពេលទុំ។

**ផ្កា (តូច)**
ផ្កាតូចមួយក្នុងចំណោមផ្កាតូចៗទាំងឡាយ ដែលបង្កើតបាន ជាបណ្តុំ ឬកន្សោមផ្ការបស់ស្មៅ។

**ផ្កាចង្កោម**
កញ្ចុំផ្កាទោល ដែលមានផ្កាដុះតំរៀបលើទងផ្កាខ្លីៗមានប្រវែង ស្មើរតែស្មើ ដែលនៅក្នុងចំងាយស្មើគ្នានៅខាងចុងទងវែងមួយ។

**ផ្លែ (គ្មានសាច់ មានតែសំបក និងគ្រាប់)**

ផ្លែ ដែលសំបកគ្រាប់ប្រេះបែកពេលស្ងួត និងមានឡត គ្រាប់មួយ ឬច្រើន។

**ផ្លែ (តូចៗ)**
ផ្លែ ដែលមានរាងតូចមូលដូចបាល់ ឬពងក្រពើ សំបូរដោយ សាច់ជាតិទឹក។

**ផ្លែ (បន្ទាស្រោប)**
ផ្លែ ដែលរុំស្រោបដោយបន្លាតូចឆ្មារ។

**ពហុវស្ស**
ដែលអាចរស់បានច្រើនឆ្នាំ។

**មានជាតិទឹក**
ក្រាស់ពោរពេញ (សំបូរ) ដោយជាតិទឹក។

**មើម (ស្លឹក)**
ផ្នែកមួយនៃដើមនៅខាងក្រោមដី រាងជាស្វៃ នៃមើមខ្ទឹមបារាំង មើមព្រលិត ឬមើមរុក្ខជាតិប្រហាក់ប្រហែល។

**មើម/ឫស (ដើមក្រោមដី)**
ដើមនៅក្រោមដី ដូចឫស ដែលបង្កើតឫស និងជាទូទៅ មានពន្លកស្លឹកនៅផ្នែកខាងចុង។

**មូលសំប៉ែត**
ដែលមានផ្ទៃរាងមូល ឬប៉ោង។

**មុំគល់ស្លឹក**
មុំផ្នែកខាងលើចន្លោះស្លឹក ឬទងស្លឹក និងដើម ជាទីតាំង ដែលស្លឹក ឬទងស្លឹក និងផ្កាដុះចេញមក។

**រាងឆ័ត្រ**
កញ្ចុំផ្កាមានរាងដូចឆ័ត្រដែលដុះចេញពីផ្នែកកណ្តាល។

**រាងត្បូងពេជ្រ**
ដែលមានរាងដូចត្បូងពេជ្រ។

**រាងត្រីកោណ**
ដែលមានរាងដូចត្រីកោណ។

# សន្ទានុក្រម

**រាងទ្រវែង**
ដែលមានរាងវែង ក្នុងទិសដៅមួយ។

**រាងធ្មេញ (មូល)**
ដែលមានគែមដូចធ្មេញមូល ឬសំបកលាសសមុទ្រតូចៗ។

**រាងធ្មេញ (ល្អិត)**
ដែលមានរាងលយចេញ ដូចធ្មេញតូចល្អិត។

**រាងធ្មេញ (ស្រួច)**
ស្លឹកដែលមានគែមរាងដូចធ្មេញស្រួច លយចេញទៅខាងក្រៅ។

**រាងធ្មេញរណា**
ដែលមានរាងដូចធ្មេញរណា។

**រាងធ្មេញរណា (តូចៗ)**
ដែលមានរាងដូចធ្មេញរណាតូចៗ ឬល្អិតៗ។

**រាងបាតដៃ**
ដែលមានរាងដូចបាតដៃ ឬប្រអប់ដៃ។

**រាងបំពង់**
ដែលមានរាងដូចបំពង់ ឬស៊ីឡាំង។

**រាងបំពង់**
ដែលមានរាងជាបំពង់ ឬប្រហោង។

**រាងបេះដូង**
ដែលមានរាងដូចបេះដូង។

**រាងផ្លែលំពែង**
ដែលមានរាងដូចផ្លែលំពែង តូចស្រួចនៅខាងចុង។

**រាងផ្លែលំពែង (ស្រួចគល់)**
ផ្ទុយពីរាងផ្លែលំពែងដែលស្រួចខាងចុង មានរាងស្រួចនៅខាងគល់នៃស្លឹក។

**រាងពងក្រពើ**
ដែលមានរាងដូចពងក្រពើ។

**រាងមូល**
ដែលមានរាងមូលដូចបាល់ ឬស្វៃ។

**រាងស៊ុត (ស្រួចគល់)**
ផ្ទុយពីរាងស៊ុតដែលស្រួចនៅខាងចុង មានរាងជាស៊ុតដែលស្រួចនៅខាងគល់ និងមូលនៅខាងចុង។

**រាងស៊ុត (ស្រួចចុង)**
ដែលមានរាងដូចស៊ុត (មូលនៅខាងគល់ និងស្រួចនៅខាងចុង)។

**រាងស្វៃ**
ដែលមានទំរង់មូលដូចស្វៃ ឬដូចបាល់។

**រឹងមាំ**
ដែលដុះ ឬកើតឡើងដ៏រឹងមាំ។

**វុក្ខរស (ជាតិទឹក ក្នុងរុក្ខជាតិ)**
សារធាតុរាវសំខាន់ដែលមានផ្ទុកនូវសារធាតុចិញ្ចឹមធ្វើចលនាចុះឡើង ក្នុងរុក្ខជាតិ។

**រោម (ទន់)**
គ្របដណ្តប់ដោយរោមទន់ខ្លី។

**រោម (រឹង)**
រោមឆ្មារៗដែលខ្លី រឹង ស្រួច ឬមុត។

**រុំព័ទ្ធ**
ដុះលូតលាស់ដោយរុំព័ទ្ធ ឬរមូរជាស្មៀរ។

# សន្ទានុក្រម

**សាយពូជ**
បន្តពូជ ឬពង្រីកពូជ។

**ស្រទបស្លឹក**
ផ្នែកមូរ ឬបំពង់នៃរុក្ខជាតិ ដូចជានៅផ្នែកខាងក្រោម (គល់) នៃស្លឹករបស់ស្មៅ។

**ស្រួច (ខ្លី)**
ស្រួចខ្លីផ្នែកខាងចុង។

**ស្រួច (វែង)**
ស្រួចវែងផ្នែកខាងចុង។

**ស្លឹក (តួស្លឹក ពិសេសស្មៅ)**
ស្លឹកនៃតិណទេស ស្មៅ ឬរុក្ខជាតិ។

**ស្លឹករួម**
ស្លឹកដែលបានចែកជាកូនស្លឹកជាច្រើនទៀត។

**ស្លឹករួមបី**
ស្លឹករួមបី។

**ស្លឹកស្និត**
ដូចស្លាបសត្វ។ ស្លឹករួមដែលមានសេរីកូនស្លឹក ដុះនៅសងខាងនៃទងស្លឹក។

**ស្លឹកស្និតរួម**
ស្លឹកស្និតពីរ ឬច្រើនដែលដុះចេញពីទងស្លឹកតែមួយ។

**ឯកវស្ស**
រុក្ខជាតិដែលដុះលូតលាស់ក្នុងរយៈពេលមួយឆ្នាំ ឬតិចជាង និងបន្តពូជដោយគ្រាប់។

# ឯកសារយោង


1. Space J (2005). Pacific Island Ecosystems at Risk (PIER) Institute of Pacific Islands Forestry. PIER website version 5.0.20051212 (http://www.hear.org/Pier/index.html).
2. Noda K, Teerawatsakul M, Prakongvongs C and Chaiwiratnukul L (1984). Major weeds of Thailand. ISBN 974-7619-78-4. Mass & Medias Co. Bangkok, Thailand. 142 pp.
3. Holm L, Doll J, Holm E, Pancho J and Herberger J (1996). World Weeds. John Wiley & Sons Inc, New York, 1129 pp.
4. Cook BG, Pengelly BC, Brown SD, Donnelly JL, Eagles DA, Franco MA, Hanson J, Mullen BF, Partridge IJ, Peters M and Schultze-Kraft R (2005). Tropical Forages: an Interactive Selection Tool. [CD-ROM], CSIRO, DPI&F(Qld), CIAT and ILRI, Brisbane, Australia. (http://www.tropicalforages.info).
5. Western Australian Herbarium (1998–). FloraBase —The Western Australian Flora. Department of Environment and Conservation. http://florabase.calm.wa.gov.au/.
6. Naples ML (2005). Weeds of Rain Fed Lowland Rice Fields of Laos & Cambodia. Unpublished MSc thesis, University of Leiden.
7. Holm LG, Plucknett DL, Pancho JV and Herberger JP (1977). The World's Worst Weeds: Distribution and Biology. University Press of Hawaii, 609 pp.
8. Anon. (1995). Flora of China 16: 301–312. (flora.huh.harvard.edu/china/PDF/PDF16/ipomoea.pdf).
9. Stone B (1970). The Flora of Guam. Micronesica 6:380.
10. McCormack G (2006.) Cook Islands Biodiversity Database, Version 2006.1. Cook Islands Natural Heritage Trust, Rarotonga. Online at http://cookislands.bishopmuseum.org.
11. Smith AC (1981). Flora Vitiensis Nova: A new flora of Fiji. Lawai, Kauai, Hawaii. National Tropical Botanical Garden. 2:700-701.
12. Brigitta EE, Duyfjes & Kanchana Pruesapan (2004). The genus *Trichosanthes* L. (Cucurbitaceae) in Thailand 76–109. Thai Forest Bulletin (Botany) No. 32.
13. Anon. (2004) Hong Kong Flora and Vegetation. (http://www.hkflora.com/v2/leaf/euphor_show_plant.php?plantid=1003)
14. Anon. (2006). Flora of China. (http://flora.huh.harvard.edu/china/mss/volume12/Vitaceae-MO_reviewing.htm).

ACIAR

www.aciar.gov.au